ឧបសៅសង្ហា

# ប្រតិបត្តិការសឹក ចេនឡា



Lon Nol (center) in 1970. Photo by Denis Cameron.
Courtesy: Marc Cameron

## ពិនិត្យឡើងវិញនូវព្រឹត្តិការណ៍សំខាន់ៗមាននៅក្នុង ប្រវត្តិសាស្ត្រខ្មែរ

**មាតិការឿង**

សេចក្តីផ្តើម ........ 2
លើឋាន យោធា ........ 5
បុព្វហេតុ នៃសង្គ្រាម នៅឆ្នាំ ១៩៧០ ........ 14
សង្គ្រាម គ្មានប្រកាស ........ 23
ប្រតិបត្តិការសឹក ចេនឡា ........ 26
ពេលវេលា នៃ តុល្យការ ........ 37
សេចក្តីសន្និដ្ឋាន ........ 51

# សេចក្ដីផ្ដើម

គេអាចផ្តល់ នូវគុណូបការៈ ដល់ សម្តេច សីហនុ ដែលទ្រង់ បានធ្វើឲស្រុកខ្មែរ ស្ថិតនៅក្រៅសង្គ្រាម នៅស្រុកឃួន ចំនួន ១៥ ឆ្នាំ ដោយយក កិច្ចព្រមព្រៀង ទីក្រុង ស្សឺណែវ នៅឆ្នាំ ១៩៥៤ ជាកំពែង ការពារ អធិបតេយ្យភាព និង បូរណភាពទឹកដីជាតិ។ ទ្រង់ យក អព្យាក្រឹតភាព ជា ខ្សែ នាយកនយោបាយខ្មែរ លើឆាកអន្តរជាតិ តែ កត្តា អន្តរ ជាតិនេះឯង ក៏ជាចំណុចក្តៅ នៃ ទំនាស់មតិ រវាង សម្តេច សីហនុ ផ្លាក់ពីតំណែង ភៀសខ្លួនទៅជ្រកកោននៅទីក្រុង ប៉េកាំង និង អំណាចថ្មី នៅ ស្រុកខ្មែរ។

ពីទីក្រុង ប៉េកាំង សម្តេច សីហនុ អះអាងថា ការពិត សហ រដ្ឋអាមេរិក (ស.រ.អ.) មិនដែល ទទួលស្គាល់ អព្យាក្រឹត ភាព របស់ស្រុកខ្មែរ ហើយ សាកល្បងគ្រប់ល្បិច ដើម្បី បញ្ចូលស្រុកខ្មែរ ទៅក្នុងប្រព័ន្ធ O.T.A.S.E. ហើយ ធ្វើគ្រប់ បែបយ៉ាង កុំឲ អន្តរជាតិ ទទួលស្គាល់អព្យាក្រឹតភាពខ្មែរ នៅពេលដែលខ្មែរ មិនព្រមធ្វើតាមខ្លួន។ ស.រ.អ. គាំទ្រ ដោយអាក្រក់ និង ផ្ទើន ឲមានសង្គ្រាម ជាមួយខ្មែរ តាម ព្រំដែន ខ្មែរ-សៀម និង ខ្មែរ-ឃួន។ ដោយមាន ការអស់

សង្ឃឹមនឹងអាច ប្តូរ នយោបាយខ្មែរបាន, ស.រ.អ. បាន សាកល្បង សម្លាប់ បុគ្គលសីហនុ ដែលជាតំណាង នៃ អព្យាក្រឹតពិត នៅចំពោះមុខ មហាអំណាចកុម្មុយនិស្ត ទាំងឡាយ។

រីឯ រដ្ឋាភិបាលភ្នំពេញ វិញ បន្ទាប់ពី សីហនុ ធ្លាក់ពីអំណាច ក៏នៅតែរក្សាគោលការណ៍ នៃអាព្យាក្រឹតភាពដដែល តែមិនទុកវាជាតម្លៃដាច់ខាតនោះឡើយ។ យ៉ាងណាមិញ ភ្នំពេញ ស្តារ នូវអាព្យាក្រឹតភាព ក្លែងក្លាយ របស់សីហនុ ដែលនាំប្រជាជាតិ ធ្លាក់ បែរកាន់តែខ្លាំងឡើងទៅរក លោកអំណាចកុម្មុយនិស្ត។

ជាការពិត, វាគ្មានការសង្ស័យអ្វីនោះឡើយថា សន្តិភាពនៅស្រុកខ្មែរ វាអាចមានបាន ពីឆ្នាំ ១៩៥៤-១៩៧០ មិនមែនមានដោយសារ បំណង របស់អន្តរជាតិឡើយ គឺវាជានយោបាយផ្ទាល់ របស់សីហនុ។ ប្រត្យក្សភាពនេះ ដែលពួកអ្នកសីហនុនិយម គេយកមកធ្វើជា រូបមន្តដែលគេទន្ទេញមិនឈប់។ តែមកដល់ឆ្នាំ ១៩៧០ អព្យាក្រឹតភាពសីហនុ វារលុបនៅស្រពេចស្រពិល ដែលនាំឲគេលែងជឿបាន លើកឆាកអន្តរជាតិ និង នៅក្នុងស្រុកខ្មែរ។ ពាក្យស្លោកថា ‹សីហនុគឺជាការបដិសេធមនោគមវិជ្ជាបរទេស› ‹សីហនុ គឺជាសន្តិភាព› វាលែងជា កម្លាំងកៀងគរផង និងលែងជាការពិតផង។ ខ្មែរជាច្រើនចាប់ផ្តើម យល់អំពីអព្យាក្រឹតភាព ក្លែងក្លាយ របស់សីហនុ ហើយ កាន់តែ

អាចយល់បាន នូវការផ្តល់យោបល់ ពីសំណាក់ មហាអំណាច ប្រឆាំងនឹងកុម្មុយនិស្ត អំពី នយោបាយ សីហនុ នាំស្រុកខ្មែរ ដើរចូលទ្រុងកុម្មុយនិស្ត។
មកដល់ឆ្នាំ ១៩៧០, វិបត្តិ នៃ អព្យាក្រឹតភាពខ្មែរ វាជាវិបត្តិ នៃ ប្រជាជាតិខ្មែរតែម្តង ព្រោះ វា មាន កើតមាន ព្រឹត្តិការណ៍មួយចំនួន នៅស្រុកខ្មែរ ដែលជាប់ទាក់ទងផ្ទាល់នឹង វិបត្តិនោះ។ លើឋាន (sur le plan) មនោគមវិជ្ជា ឬ សង្គមនិយម ព្រះពុទ្ធសាសនា របស់សីហនុ ដែលតែងតែប្រថ្នា ស្ថិតនៅឆ្ងាយពី សេរីនិយម នៃមស្ចឹមប្រទេស និង ម៉ាក្សនិយម វាលែងមាន ទំហំនយោបាយ និង ស្ថេរភាព ដែលអាចឲគេទទួលយកបាន។ លើឋាន រចនាសម្ព័ន្ធ សេដ្ឋកិច្ច ឬ ដំណើរ នៃ ជាតិរូបនីយកម្ម, បដិសេរីនិយម ពីឆ្នាំ ១៩៦៤ ផ្តល់ចំណាប់អារម្មណ៍ ថា សីហនុនិយម កំពុង រំអិល ទៅរក សង្គមនិយម និង បរាជ័យ សេដ្ឋកិច្ច។ លើឋាន យោធា និង កិច្ចការទូត គឺជាខ្លឹម នៃ វិបត្តិ បញ្ចេញឲឃើញថា នៅក្នុងទឹកដីខ្មែរ មានទ័ពយួន កុម្មុយនិស្ត តាំងនៅជាចិរកាល ដែលវាខុសពីគោលការណ៍ នៃសន្ធិសិទ្ធ ស៊្សឺណែវ។ ដូច្នេះ សម្តេច សីហនុ ទ្រង់តែងតែ ឆ្លៀតយកផល ពី ប្រធានបទ នៃ អព្យាក្រឹតភាព វាមកដល់កំរិតមួយ ដែលទ្រង់ អាចនិយាយបាន តែ ទ្រង់ ពុំអាចអនុវត្តវាបាន នោះឡើយ។

ដូច្នេះ សន្តិភាពខ្មែរ នៅឆ្នាំ ១៩៧០ មានន័យ មិនដាច់ ខាតនោះឡើយ។ បន្លក នៃ អសន្តិសុខ ចាប់ផុះចេញ ហើយវានឹងអាច ដុះរាលដាល ដែលនឹងនាំឲ ប្រជាជាតិ អាចជួបប្រទះនឹង គ្រោះថ្នាក់។ គ្រោះថ្នាក់នោះ វាក៏មាន កើតពិនមែន ក្រោយពីថ្ងៃទី ១៨ មីនា ឆ្នាំ ១៩៧០។ គ្រោះ ថ្នាក់នោះ គេបែងចែក កន្លែងឈរះភ្លើងខ្លាំង របស់វា ៤ កន្លែង : កិច្ចបណ្តាលរឿងហេតុ នៃ យួនខាងត្បូងនៅ តាមព្រំដែន, ចលនាខ្មែរសេរី, ការបះបោរនៅក្នុងប្រទេស និង ការរុកចូល នៃ ពួកយៀកកុង។

## ១. កិច្ចបណ្តាលរឿងហេតុ នៃយួនខាងត្បូង

គឺជា ការទទួលថ្នបាក់ ពីសង្គ្រាម នៅ ស្រុកយួន។ ឧប្បត្តិ ហេតុ ទី១ គឺកើតឡើង នៅ ស្រុក បូកែវ នៅឆ្នាំ ១៩៥៨។ បន្ទាប់មក វាកាន់តែមាន បន្តៗទៀត គ្មានដាច់។ ជួនកាល វាគឺជា ការលុកលុយ តូចៗមួយចំនួន, ការ រំលោភ ព្រំដែន មិនធ្ងន់ធ្ងរ ; ជួនកាល ជា ឧប្បត្តិហេតុ អ ស្ចារ្យ ដូចយ៉ាង ការទំលាក់គ្រាប់បែក លើភូមិ ចន្ទទ្រា នៅ ឆ្នាំ ១៩៦៦, នៅភូមិ ដាក់ដាំ នៅឆ្នាំ ១៩៦៩។ ខាង អាមេរិ កាំង និង យួនខាងត្បូង គេអះអាងថា វាគឺជា ការច្រឡំ ដែលមិនអាចជៀសបាន កើតពីស្ថានភាព នៃសមរភូមិ។ ក្នុងចំណុចនេះ គេលើកឡើងថា មកពី លក្ខណៈ នៃ ព្រំ

ដែន មិនច្បាស់លាស់ និង ការរត់ចូល នៃ ពួកយៀកកុង មកក្នុងស្រុកខ្មែរ ដែល គេអាចមានសិទ្ធិ ដេញតាមសត្រូវ មកធ្វើជា ការសំអាង។ ជួនកាល គេសុំទោស ហើយ សង ជាជម្ងឺចិត្ត ជួនកាល គេចោទប្រកាន់ លើអព្យាក្រឹតក្លែងក្លាយ តែម្តង។

ខាង សម្តេច សីហនុ ការវិភាគ វាខុសគ្នា។ ឧប្បត្តិហេតុ ម្តងហើយម្តងទៀត គឺជា នយោបាយជាប្រព័ន្ធ នាំយក ស្រុកខ្មែរ បញ្ចូលដោយប្រយោល ទៅក្នុងសង្គ្រាម ជួយអាមេរិកាំង តាម ការធ្វើ ប្រតិបត្តិការសឹករួម។ ព្រំដែន ដែល បារាំងទុកឲ្យខ្មែរ ហាក់ដូចជាគ្រប់គ្រាន់ ព្រោះថា ចាប់ពី ឆ្នាំ ១៩៦៦ ព្រំដែន រាជរដ្ឋាភិបាល យកមកប្រើជាមូលដ្ឋាន សំរាប់ធ្វើសកម្មភាពទូតទាំងឡាយ។ ជាដំបូង សម្តេច សីហនុ ទ្រង់ បដិសេធ នូវវត្តមាន ពួកយៀកកុង នៅក្នុងទឹកដីខ្លួន, បន្ទាប់មក ថាជា កិច្ចការសុទ្ធសាធ របស់ខ្មែរ ហើយ រាជរដ្ឋាភិបាលខ្មែរ និង កងទ័ពជាតិ តែងតែប្រយុទ្ធប្រឆាំង មិនដាច់ ហើយអះអាងថា វាមាន លទ្ធផល ជាក់ច្បាស់។ តែការដោះសារនេះ វាមានវិសាលភាពមានកំណត់[1]។

ការវិភាគដែលបានជ្រើសរើស អ្វីក៏ដោយ លើ ឧប្បត្តិហេតុ ទាំងឡាយ ដែលមានកើតឡើង វាមានប៉ះពាល់ លើតែ ប្រជាជន រស់នៅតាមព្រំដែន តែប៉ុណ្ណោះ ហើយ នៅទី

[1] Une portée limitée.

កន្លែង ដែលមានមនុស្សរស់នៅតិចតួចណាស់ តែ រាជរដ្ឋាភិបាលខ្មែរ ជួនកាល យកវាមកឃោសនា បំប៉ោង ជាផ្លូវការ ដើម្បី យកចំណេញនយោបាយ។ តែ លទ្ធផល វានាំឲមានភាពចម្រូងចម្រាស ដល់ខ្លួនឯងទៅវិញ ស្ថិតិវត្តមាន ពួកយៀកកុង ក្នុងស្រុកខ្មែរ ដែលនាំឲមាន ការលើកឡើង អំពី ‹សិទ្ធិដេញតាមសត្រូវ› ដែល ជា ការកំហែងមួយ ដល់អនាគត។ ការកំហែងនេះ វាបង្ហាញ អំពីអ្វីដែលនឹងកើតឡើង នៅឆ្នាំ ១៩៧០។

នៅខែសីហា ឆ្នាំ ១៩៧៣, សារព័ត៍មាន « le Monde » បង្ហាញថា រដ្ឋបាល លោកប្រធានាធិបតី Nixon បានអនុញ្ញាតឲទំលាក់គ្រាប់បែក ជាប្រព័ន្ធ មកលើស្រុកខ្មែរ តាំងពីមុនថ្ងៃទី១៨ មីនា ឆ្នាំ ១៩៧០ មកម្លេះ។ ការណ៍នេះអាចចាត់ទុកជាភស្តុតាងមួយថា អន្តរាគមន៏អាមេរិកាំង មិនអាចបដិសេធបាន នៅស្រុកខ្មែរ មិនមែនកើតមកពីការរាតត្បាតពួកយៀកកុង ក្រោយពី សម្តេច សីហនុ ធ្លាក់ពីតំណែង នោះទេ។ សម្តេច ខ្លួនឯង ទ្រង់ក៏បានសារភាពថា ទ្រង់បានអនុញ្ញាត ឲ អាមេរិកាំង ទម្លាក់គ្រាប់បែក នៅស្រុកខ្មែរ កាលទ្រង់ នៅកាន់អំណាច ដោយសារពួកយៀកកុង វាឈ្លានពានទឹកដីខ្មែរ កាន់តែខ្លាំងៗ។

## ២. ពួកខ្មែរសេរី

ពួកខ្មែរសេរី ដឹកនាំដោយ លោក សឺន ង៉ុកថាញ់ មិនទុកជាគ្រោះថ្នាក់ធំ លើឋាន យោធា នោះទេ។ ចលនានេះធ្វើសកម្មភាព បន្តពីសម័យអាណាមិគមនិយម ប្រឆាំងនឹង បារាំង និង សីហនុ នៅអំឡុងឆ្នាំ ១៩៤៧-៥៤ ហើយបន្ត ធ្វើបដិវត្តន៍មួយដ៏ចម្លែក។

លោក សឺន ង៉ុកថាញ់ ជាអ្នកជាតិនិយម ដាច់ខាតប្រឆាំងនឹងបារាំង និង រាជានិយម។ នៅសម័យបារាំងកំពុងជួបប្រទះ នូវការរំដើបរំជួលនយោបាយ នៅឥណ្ឌូចិន, អាផ្ទាធរ បារាំង មានការពិបាកនឹងចាត់ទុកសឺន ង៉ុកថាញ់ ជា អ្នកបដិវត្តន៍ បែបណាពិប្រាកដ, ជាទូទៅ គេគ្រាន់តែ ចាត់ទុកគាត់ ជា អ្នកប៉ះបោរធម្មតាម្នាក់ តែប៉ុណ្ណោះ។ លោក សឺង ង៉ុកថាញ់ មានទំនាក់ទំនងជិតស្និត ជាមួយ ពួក ខ្មែរយៀកម៉ិញ ច្រើនជាង ខ្មែរសេរី តែ នៅពេលនោះ ហាក់បី លោក ជា ឥស្សរជននយោបាយម្នាក់គត់ ដែលអាច ធានា នូវការទំនាក់ទំនង រវាងនិន្នាការ នយោបាយ ផ្សេងគ្នាៗ និង ចងជាសហព័ន្ធ នៃក្រុមពួកអ្នកប៉ះបោរទាំងឡាយបាន។ លោក ជា ចមជនរងគ្រោះ នឹង រាជបូជនីយកិច្ច ដើម្បី ឯករាជ្យជាតិ ដឹកនាំដោយ សម្តេច សីហនុ។ ក្សៀយនោះ សីហនុ បើកទ្វារឲ ពួកកុម្មុយនិស្ត ចូលរួបរួម ក្នុងល្បែងនយោបាយជាតិ របស់ព្រះអង្គ គឺ អព្យាក្រឹតភាព។ ចំណែក លោក សឺង ង៉ុកថាញ់

ជា ចមកស្សេរជននយោបាយ, សីហនុហាក់បីដូចជា មិន
ឲលោក មាន លទ្ធភាព អាច ស្នើដល់ប្រជាជាតិ នូវ
ជម្រើសនយោបាយផ្សេងមួយ ខុសពីព្រះអង្គ ដែលនាំ
ឲគាត់ ជ្រើសយក នូវការតស៊ូអាវុធ ប្រឆាំងនឹងព្រះអង្គ។
តែសកម្មភាព យោធា របស់គាត់ គឺស្ថិតនៅតែតាម ព្រំ
ដែន ខ្មែរ-សៀម នៅក្នុង ដំបន់ព្រៃភ្នំ ដែលពិបាកនឹង
ចូលទៅដល់ ហើយ មាន សកម្មភាពយោធា តិចតួចណា
ស់។ ហើយ នៅពេលនោះដែរ ព្រឹត្តិការណ៍ អន្តរជាតិ ទាំង
ក្នុងប្រទេស និង ក្រៅប្រទេស មិនផ្តល់ជូនគាត់ នូវសន្លឹក
បៀ សំរាប់លែង។ ជាសត្រូវនឹង សីហនុ មុនអ្វីៗទាំងអស់,
ដូច្នេះ គាត់នៅសល់តែ ការស្វែងរក នូវការគាំទ្រ ពីសត្រូវ
រួម ប្រឆាំងនឹង សីហនុ តែប៉ុណ្ណោះ ដូចជា យួនខាងត្បូង
និង សៀម តាមរយៈអាមេរិកាំង។ គាត់ ទទួលបាន នូវ
ការឧបត្ថម ពីប្រជាជន មួយចំនួន ក្នុងចំណោម ជន
ជាតិខ្មែរភាគតិច រស់នៅក្នុងប្រទេសទាំងពីរនោះ។ តែ
នៅពេលនោះ នៅក្នុងស្រុកខ្មែរ អ្វីដែលជា សត្រូវនឹងសីហ
នុ ខ្មែរភាគច្រើន ទុកជា សត្រូវនឹង ប្រជាជាតិខ្មែរ គឺថា
ជា ជនក្បត់ជាតិ។
ចាប់ពីឆ្នាំ ១៩៦៨, គេមានចំណាប់អារម្មណ៍ថា ចលនា
ខ្មែរសេរី ចាប់មានសន្ទុះ ដោយសារមាន ការចុះចូល ពី
សំណាក់ខ្មែរកម្ពុជាក្រោមទាំងនៅកម្ពុជាក្រោម និង កម្ពុ
ជាកណ្តាល ហើយចងគ្នា ជាកម្លាំងនយោបាយមួយ ដែល

អាចនាំមកនូវគ្រោះថ្នាក់ដល់សម្ដេចសីហនុ។ ក្រោយមក កម្លាំងនោះ វាហាក់បីដូចជា ស្ថិតនៅក្នុងកណ្ដាប់ដៃ របស់ សត្រូវ នៃ សីហនុ នៅភ្នំពេញ តែម្ដង។ ទ្រង់ យល់ដឹង អំពី គ្រោះថ្នាក់នោះ តែ ទ្រង់ ពុំអាចធ្វើអ្វីប្រឆាំងនឹងវាបាន នោះឡើយ ព្រោះ វារស់នៅក្នុង ចលនាសង្គមរាស្ត្រនិយម តែម្ដង។ នៅឆ្នាំ ១៩៦៩ មានផ្ទុះ ករណីមួយ នៅភ្នំ មាលៃ គឺ ខ្មែរសេរី ចំនួនជាង ១០០ នាក់ សូមចុះចូលនឹង សីហ នុ។ តែមានមតិខ្លះយល់ឃើញថា ការណ៍នេះ ជា ប្រតិបត្តិ ការ បញ្ចូល ពួកខ្មែរសេរី មកក្នុងក្រុងភ្នំពេញ ដើម្បី ចូល រួមទំលាក់សម្ដេច សីហនុ ជាមួយកម្លាំង ខាងក្នុង។

## ៣. ការប៉ះបោរ បង្កឡើង

ត្រូវធ្វើការបែកចែក រវាង ការបះបោរ កសិករ មានកើត ឡើងនៅឆ្នាំ ១៩៦៧ ហើយ ព្រាចបន្តិចម្ដងៗ តាមជនបទ និង ចាប់ពីឆ្នាំ ១៩៦៨ មានការបង្កោះ (secouer) នៃប ណ្ដាជន រស់នៅលើភ្នំ នៅខេត្ត តាមព្រំដែន ពាយ័ត្យ (រតនគីរី, មណ្ឌលគីរី)។

ការបះបោរ កសិករ នៅឆ្នាំ ១៩៦៧ នាំឲមាន ភាពចម្រូង ចម្រាស និង ការរិភាពខុសៗគ្នា។ អ្នកសង្កេតការបរទេស ខ្លះ ទុកការបះបោរនោះ ជាបរាជ័យ នៃប្រព័ន្ធដឹកនាំ និង ការបំពាន នៃពួកនាម៉ឺន។ តាមយោបល់ សម្ដេច សីហនុ, ទ្រង់យល់ឃើញថា ជាស្នាដៃ របស់ពួកកុម្មុយនិស្ត, សង្គរ

ដោយបរទេស ហើយទ្រង់បដិសេធ ប្រកបដោយការឈឺចិត្តថា គ្មាននរណាជំទាស់នឹង អំណាច របស់ទ្រង់នោះទេ ហើយ វានាំឲមានការប្រេះឆា ដល់ សាមគ្គីជាតិ ដែលទ្រង់ជាតំណាង នោះផង។ តាមទ្រង់ ការបះបោរនោះ គឺ ជាការប្រឆាំងនឹង នយោបាយរីបជាន់ នៃ រាជការ។

ការណ៏នេះ, គេមិនអាចជំទាស់បានថា វាគ្មានមូលដ្ឋានពិត នៃប្រជាចលនា នោះបានឡើយ។ វាមានពិត នូវការបំពាន លើប្រជាកសិករ ពីសំណាក់ ពួកមន្រ្តីរាជការខែត្រមួយចំនួន ដែលជា ពួកអ្នកអបអម ព្រះរាជវង្សានុវង្សទទួលបានដំណែង ជា ចៅហ្វាយខែត្រ និង មុខដំណែងផ្សេងៗទៀត។ ដូច្នេះ វាមានការពិបាកនឹងហួត ការទទួលខុសត្រូវ របស់សម្តេច សីហនុ។ តែ ការមិនសប្បាយចិត្តរបស់ប្រជាជន នោះ គឺភ្លាមឡើង ត្រូវបាន ពួកកុម្មុយនិស្ត យកមក គ្រប់គ្រងបាន និង បញ្ចូល ទៅក្នុង យុទ្ធសាស្ត្របក្ស ដើម្បីជំទាស់នឹង នយោបាយបរាជ័យ នៃការបង្រួបបង្រួមជាតិ របស់សម្តេច សីហនុ។

រីឯ តួនាទីបរទេស វិញ វាពិបាកនឹងបញ្ជាក់ឲឃើញច្បាស់លាស់។ តែមាន អ្នកសង្កេតការបរទេសខ្លះ ជឿជាក់ថាពួកកុម្មុយនិស្ត ចិន និង យួន ជាអ្នកនៅពីក្រោយ និងជាអ្នកដឹកនាំផ្ទាល់ នៃឧទ្ទាមកម្មនោះ ព្រោះពួកគេ មិនអាចឲឱកាសដ៏កំរមាននោះ គឺ ប្រជាបះបោរ និង មានលក្ខណ:ជាតិពិត ប្រឆាំងនឹង រដ្ឋាភិបាល ស្តាំនិយម របូត

ពីដៃគេបាននោះទេ។ តែពួកគេ ត្រូវធ្វើយ៉ាងណា កុំឲការ បះបោរនោះទង្គិច ជាជម្លោះនឹង សម្ដេច សីហនុ ដែលគេ ចាត់ទុកជា អ្នកអ្នកដឹកនាំ ជាតិនិយម និង ជឿនលឿន និយម។ ដូច្នេះ ការធ្លាក់ពីដំណែង នៃសីហនុ វានាំអាចឲ ពួកស្តាំនិយមជ្រុល មានសុភចិត្តនឹង អាមេរិកាំង អាច នឹងឡើងកាន់អំណាច។

នៅក្នុង បរិបទនេះ វាហាក់បីដូចជា ពួកកុម្មុយនិស្ត គ្មាន ទំនងអ្វីនឹងធ្វើឲជម្លោះនឹងសីហនុ រីកធំឡើងនោះឡើយ។ តែ ចំពោះ ពួកនោះ ការបើកឲមានអសន្តិសុខ មានកំរិត ខ្លះ ជាមួយ សីហនុ ជា ការបម្រុងទុក ក្នុងករណី ដែលអាច នឹងមានការប្តូររបប។ តែចំពោះ សម្ដេច សីហនុ ឧទ្ទាម កម្ម ដែលកើតមានឡើងនោះ ទ្រង់ទុក ជា ការមើលងាយ ដល់ព្រះអង្គផ្ទាល់ពីសំណាក់ ចិន និង យួនកុម្មុយនិស្ត ដែលនាំឲទ្រង់ ឆ្លើយតបវិញ តាម មធ្យោបាយសាហាវ ហើយជួនកាល ហួសហេតុ ពីសំណាក់ កងទ័ព និង ប៉ូលិស។ មួយវិញទៀត ការបះបោរ នៃ ប្រជាជនភ្នំ ក្នុងខេត្ត រតនៈ គីរី នៅឆ្នាំ ១៩៦៨, សម្ដេច សីហនុ បានចោទប្រកាន់ថា ជាស្នាដៃ នៃពួកយួនយៀកកុង ព្រោះដំបន់នោះ ជាដំបន់ យុទ្ធសាស្ត្រសំខាន់ របស់យួនកុម្មុយនិស្ត ក្នុងក្របខណ្ឌ ចម្បាំងនៅស្រុកយួន។

## ៤. ការតាំងទ័ពយៀកកុង នៅលើទឹកដីខ្មែរ

អាមេរិកាំង និង យួនខាងត្បូង តែងតែចោទប្រកាន់ថា ពួកយៀកកុង ប្រើទឹកដីខ្មែរ ជាមូលដ្ឋាន ដកថយទ័ពផង និង វាយលុកផង មកលើកងទ័ពខ្លួន។ ពួកគេមានភស្តុតាង ជាច្រើនថា ពួកយៀកកុង តែងតែមកសំរាកទ័ព និង ព្យាបាលជម្ងឺ និង របួស គ្រប់បែបយ៉ាង នៅក្នុងពេទ្យ ដែលពួកវាសង់នៅក្នុងស្រុកខ្មែរ។ លើសពីនេះទៅទៀត ពួកយៀកកុង បាន តាំង ជំរុំហ្វឹកហាត់ទាហ៊ាន និង ឃ្លាំង សម្ភារៈយោធា។ ទីតាំងទាំងនោះ ជា ជម្រកមាំមួនមិនអាចនរណា អាចរំលោភបាននោះឡើយ។ អាមេរិកាំង រហូតមានជំនឿថា ទីស្ដីការ នៃ រដ្ឋាភិបាល បណ្ដោះអាសន្ននៃសាធារណរដ្ឋ យៀកណាម (G.P.R.V.N.) ស្ថិននៅក្នុងស្រុកខ្មែរ តែម្ដង។

ពួកកុម្មុយនិស្តយួន តែងតែបដិសេធជានិច្ច នូវការចោទប្រកាន់នោះ។ រីឯ សម្ដេច សីហនុ វិញ ទ្រង់ មានការប្រយ័ត្នណាស់ ក្នុងការបកស្រាយរឿងនោះ ព្រោះព្រះអង្គជាអ្នកអនុញ្ញាត : នៅស្រុកខ្មែរ គេទុករឿងនោះ ជា ឧត្តមនយោបាយ របស់សម្ដេចឪ។ រហូតមកដល់ឆ្នាំ ១៩៦៩ ព្រះអង្គ មិនអាចលាក់បាំងរឿងនោះបានទៀតឡើយ ចំពោះអន្តរជាតិ, ដូច្នេះ ទ្រង់ បានចុះផ្សាយនៅក្នុង សារព័ត៌មាន បង្ហាញ ផែនទី នៃ ទីតាំងទ័ពយៀកកុង នៅក្នុងទឹកដីខ្មែរ, តែ ទ្រង់បានបញ្ជាក់ថា ពួកអ្នកដឹកនាំយួន

កុម្មុយនិស្ត គេបានសន្យានឹងទ្រង់ថា គេនឹងដកទ័ពនោះ ចេញពីស្រុកខ្មែរភ្លាម នៅពេលឈប់មាន សង្គ្រាមនៅស្រុកយួន។

## បុព្វហេតុ នៃសង្គ្រាម នៅឆ្នាំ ១៩៧០

តើ សង្គ្រាម នៅប្រទេសយៀកណាម ជាបុព្វហេតុ នៃសង្គ្រាម នៅកម្ពុជា ?

ប្រទេស កម្ពុជា រស់ នៅ ក្បែរ សង្គ្រាម នៅ យៀកណាម អស់រយៈច្រើន ទស្សវត្សរ៍ មកហើយតាំង ពីសង្គ្រាម បារាំង ជា មួយ កងកម្លាំងទ័ពបដិវត្ត កុម្មុយនិស្តយួន ផ្ដើមកើតឡើង ក្នុង ទស្សវត្សរ៍ទី ៤០ រហូត មកដល់ សង្គ្រាម រវាង យៀកណាម ខាងត្បូង ដែលមាន ស.រ.អ. ជា សម្ពន្ធមិត្ត ចូលរួម ធ្វើសង្គ្រាម ក្នុងទស្សវត្សរ៍ទី ៦០ ប្រឆាំងនឹង រណសិរ្សជាតិ រំដោះ យៀកណាម ខាងត្បូង ហៅ ថា យៀកកុង ដែលជា សាខាយោធា នៃសាធារណរដ្ឋ សង្គមនិយម ហៅ ថា យៀកណាម ខាងជើង ដែល មាន លោកកុម្មុយនិស្ត មានជា អាចិ សហភាពសូវៀត និង ចិនប្រជាមានិត ជា អ្នកផ្ដល់ជំនួយ គ្រប់បែបយ៉ាង។ សង្គ្រាម នៅយៀកណាម នេះ ជា សង្គ្រាម មួយ នៅក្នុង សង្គ្រាមត្រជាក់ រវាង ប្លុក លោកសេរី នឹង ប្លុក លោកកុម្មុយនិស្ត ក្រោយ ពី សង្គ្រាម លោក លើក ទី២។ ចំពោះលោកសេរី យៀកណាម ជា ច្រក ចូល នៃ លទ្ធិកុម្មុយនិស្ត ក្នុងដំបន់ អាស៊ីភាគអគ្នេយ៍

មានប្រទេស សៀម ភូមា លាវ កម្ពុជា និង យៀកណាម។ បើ យៀកណាម ដួល ដោយ ខ្យល់កុម្មុយនិស្ត គឺ វា នឹង នាំ ៦ ប្រទេស នៅក្នុង ដំបន់ អស៊ីភាគអគ្នេយ៍ ដួលបន្ត បន្ទាប់គ្នា ជា ពុំខាន ដូចជា «ល្បែកដូមីណូ» នោះឯង។ ទស្សនៈ នេះ បាន ត្រូវ ស.រ.អ. យក មកធ្វើជាទ្រឹស្ដីនយោបាយ ទុក លទ្ធិកុម្មុយនិស្ត ជា អភិទ្រោះ (ការគំរាម) នៅអាស៊ី។ ក្រោយពី សន្និសិទ្ធ នៅទីក្រុង ស៊្សឺណែវ (២១ កក្កដា១៩៥៤) នៅ ថ្ងៃទី ៨ កញ្ញា ១៩៥៤ នៅ ទីក្រុង ម៉ានិល នៃ ប្រទេស ហ្វីលីពិន ប្លុក លោក សេរី បាន បង្កើត អង្គការការពាររួម មួយ មាន ឈ្មោះ ថា «អង្គការ នៃ សន្ធិសញ្ញា នៃ ប្រទេស អាស៊ី ភាគ អគ្នេយ៍» (SEATO)។ អង្គការនេះ មាន គោលដៅ ទប់ទល់នឹង ការវាតទី នៃកម្លាំងកុម្មុយនិស្ត នៅតណ្ឌូចិន និង ដំបន់ អាស៊ីទាំងមូល។

សង្គ្រាម ត្រជាក់ រវាង ប្លុក លោកសេរី នឹង ប្លុកលោកកុម្មុយនិស្ត នាំបង្កើត៩មាន ក្រុមប្រទេស មិនចូល ប្លុកណាមួយ ក្នុងនោះ មាន សមាជិក ជា ប្រទេស ដែលទើបតែបាន ឯករាជ្យ ពី អាណានិគមនិយម ហើយ មាន សេដ្ឋកិច្ចទន់ខ្សោយ។ អង្គការនេះ ជា ប្លុក ទី៣ ដែល មាន ឈ្មោះ ថា ប្លុក តតិយលោក។ ប្រទេសកម្ពុជា នៅ ក្រោមនយោបាយ សម្ដេច សីហនុ បាន ជ្រើសរើស មាគ៌ានយោបាយ ការបរទេស របស់ខ្លួន ដោយប្រកាន់យកគោល ជំហរ អព្យាក្រឹតភាព ហើយ បាន ចូល ធ្វើ ជា

សមាជិក នៃ ក្រុមមិនចូលប្លុកណាមួយ ដើម្បី រក តុល្យាភាព នៃ នយោបាយការបរទេស។ នៅក្នុង ឆ្នាំ ១៩៥៧ សម្តេច សីហនុ សម្រេចចិត្ត ទទួល ជំនួយ សេដ្ឋកិច្ច ពីប្រទេស ចិនប្រជាមានិត បន្ថែម លើ ជំនួយ អាមេរិកាំង ដែល ប្រទេស កម្ពុជា បានទទួលយក តាំងពីឆ្នាំ ១៩៥៥ មកម្លេះ។ របត់ នយោបាយ នេះ នាំបង្កើត ឲ មាន បញ្ហាស្មុកស្មាញ ជា ច្រើន នៅក្នុង ការទំនាក់ទំនង ជាមួយ ស.រ.អ. ដែល កំពុង ដើរតួ ជា មេដឹកនាំ ប្រឆាំងនឹង កុម្មុយនិស្ត នៅក្នុងពិភពលោក។ ការរំកិល កាន់តែខ្លាំងៗ នៃប្រទេស កម្ពុជា ទៅរក ប្រទេសចិនប្រជាមានិត តម្រូវ ឲ សម្តេច សីហនុ គាំទ្រ មិនចេញមុខ ដល់ កម្លាំង តស៊ូ យួន កុម្មុយនិស្ត នៅ ប្រទេស យៀកណាម ខាងត្បូង។ ទំនោរ នេះ នាំបង្កើតឲមានភាពតានតឹង ជាមួយ សាធារណរដ្ឋ យៀកណាម ខាងត្បូង ដែល កំពុងតែ ទទួលការវាយប្រហារ ពី កម្លាំងកុម្មុយនិស្តយួន។

ចាប់ ពីឆ្នាំ ១៩៦៣ សង្គ្រាម នៅយៀកណាម កាន់តែមានសន្ទុះខ្លាំងឡើងៗ រវាង កងទ័ពយៀកណាមខាងត្បូង នឹង យៀកកុង ដែលនាំ ឲ មាន ការរាលដាល នៅតាមព្រំដែន ខ្មែរ-យៀកណាមខាងត្បូង នាំឲកងកម្លាំងទ័ពយៀកណាមខាងត្បូង ចូល មកក្នុងទឹកដីខ្មែរ ដើម្បី តាមវាយប្រហារ យៀកកុង ដែលរត់ចូលមកពួន។ នៅចំពោះមុខ បញ្ហានេះ សម្តេចសីហនុ បាន សុំ ជំនួយ យោធាបន្ថែម ពី

ស.រ.អ. ដើម្បី ពង្រឹង និង កែទម្រង់ កងទ័ព ខេមរភូមិន្ទខ្មែរ ឲទំនើប តែព្រះអង្គ ក៏បានស្នើ ទៅចិនប្រជាមានិត សុំជំនួយ ផ្នែកយោធា បន្ថែម លើ ផ្នែកសេដ្ឋកិច្ចដែរ។ លើសពីនេះ ព្រះអង្គបានស្នើដល់ ស.រ.អ. ឲ ជួយ រៀបចំ ឲ មាន សន្និសិទ្ធ អន្តរជាតិមួយ ដើម្បី រកការធានា និង ការគោរព បូរណភាព ទឹកដីខ្មែរ ពីសំណាក់ប្រទេសជិតខាង។ តែសំណើរ នេះមិនមានការគាំទ្រ ពី ស.រ.អ. ដោយ សំអាងថា វា គ្មាន ប្រសិទ្ធភាព ច្រើនជាង ការពង្រឹង ទំនាក់ទំនង ជាទ្វេភាគី រវាង កម្ពុជា នឹង ស.រ.អ. នោះទេ។ តែទោះបីយ៉ាងណា តាម លិខិត លោក ប្រធានាធិបតី Kennedy លោក បានបញ្ជាក់ដល់ សម្ដេចសីហនុ នូវ ការគោរព និង ធានា ការពារ បូរណភាពទឹកដីខ្មែរ ពីសំណាក់ ស.រ.អ.។ ឧប្បត្តិហេតុ កើត មាន ក្នុង ឆ្នាំ ១៩៦៣ គឺ ការវាយប្រហារ ភូមិខ្មែរមួយ ពីសំណាក់ កងកម្លាំងទ័ព យៀកណាម ខាងត្បូង នាំ ឲ សម្ដេច សីហនុ បញ្ចប់ នៅ ខែសីហា នូវទំនាក់ទំនងតាមផ្លូវទូត ជាមួយ សាធារណរដ្ឋ យៀកណាមខាងត្បូង។ ក្រោយពីលោកប្រធានាធិបតី Kennedy ត្រូវ បាន គេ ធ្វើឃាតលោក, ទំនាក់ទំនង រវាង ស.រ.អ នឹង កម្ពុជា មាន ការចុះអន់ថយ កាន់តែខ្លាំងឡើងៗ រហូត ដល់ សម្ដេច សីហនុ មើលងាយ សពលោក អតីតប្រធានាធិបតី ស.រ.អ. ថា ជា «ចៅហ្វាយធំ នៃ ពួកអ្នកឈ្លានពាន»។

ឧប្បត្តិហេតុ នៅ ឈូងសមុទ្រ តុងកឹង រវាង កងនាវា អាមេរិក និង យៀកណាមខាងជើង នៅ ក្នុង ឆ្នាំ ១៩៦៥ នាំពង្រីក សមរភូមិ នៃសង្គ្រាម នៅយៀកណាម គឺការសម្រេចចិត្ត របស់ ស.រ.អ. ធ្វើការទម្លាក់គ្រាប់បែប នៅយៀកណាមខាងជើង ដែល ស.រ.អ. តែងតែ ទុកជា ជាចៅហ្វាយផ្ទាល់នៃពួកយៀកកុង។ លើសពីនេះ ស.រ.អ. បាន បញ្ជូន កងទ័ពជើងគោក មកកាន់ ប្រទេស យៀកណាមខាងត្បូង ដើម្បីជួយច្បាំង កងទ័ពយៀកណាមសេរី ប្រឆាំងនឹង កងទ័ព យៀកកុង។ នៅចំពោះមុខ ស្ថានភាពថ្មីនេះ នៅ ខែ ឧសភា សម្តេច សីហនុ បាន បញ្ឈប់ នូវការទំនាក់ទំនងទូត ជាផ្លូវការ ជាមួយ ស.រ.អ. ហើយ អនុញ្ញាត ជា សម្ងាត់ ឲ ពួក យៀកកុង ចូលមកក្នុងទឹកដីខ្មែរ ដើម្បីបង្កើត មូលដ្ឋានទ័ពក្រោយ សំរាប់គាំទ្រ សមរភូមិមុខ នៅ យៀកណាមខាងត្បូង។ ចំនួន យោធា យៀកកុង មកតាំងទី នៅក្នុងស្រុកខ្មែរ មាន ប្រមាណ ៦ម៉ឺន នាក់ រីឯ កងទ័ព ខេមរភូមិន្ទខ្មែរ វិញ មាន ចំនួន តែ ៣ ម៉ឺន នាក់ តែប៉ុណ្ណោះ។ យៀកកុងបាន បន្ត សាង ផ្លូវលំ ហូជីម៉ិញ ចូល មក ក្នុង ស្រុកខ្មែរ សំរាប់ ដឹកជញ្ជូន ជំនួយ យោធា ពីសំណាក់ អង្គការយោធា ហ្វាសូវី ចេញ ពី កំពង់ផែ កំពង់សោម ឆ្ពោះ ទៅ កាន់ សមរភូមិ នៅ យៀកណាមខាងត្បូង។ ឯកសារមួយ បរហារ ថា ប្រទេស កម្ពុជា យក ជា កម្រៃ ១០% ពីចំនួន ជំនួយនោះ។ ប៉ុន្តែ នៅ ពេល

នោះ យៀកកុង គេ យក ប្រទេស កម្ពុជា ជា មូលដ្ឋាន សេដ្ឋកិច្ច សំរាប់ ទ្រទ្រង់ រណសិរ្ស របស់គេ។ ឯកសារសម្ងាត់ មួយដែរ បរិហារ ថា ចំនួន ១ ភាគ ៤ នៃផលិតផល ស្រូវខ្មែរ ត្រូវបាន យៀកកុង ទិញយក ទៅចិញ្ចឹម កងទ័ពគេ ដែលកំពុងបំពេញ បេសកកម្មសឹក នៅយៀកណាមខាងត្បូង។ ដើម្បី វាយ បំផ្លាញ មូលដ្ឋានយោធាយៀកកុង នៅ កម្ពុជា លោក ប្រធានាធិបតីអាមេរិក Lyndon Johnson បានអនុញ្ញាតិ ៤ កង ទ័ព អាមេរិកាំង ធ្វើប្រតិបត្តិការសឹក សំងាត់ ចូល មក ក្នុង ទឹកដីខ្មែរ។ នៅឆ្នាំ ១៩៦៨, ឆ្លើយ តប ទៅ នឹង សេចក្តីរាយការណ៍ នៃបេសកកម្ម នៃ រដ្ឋាភិបាល ស.រ.អ. មក កម្ពុជា ដឹកនាំដោយ លោក Chaster A. Bowles ស្តីពី វត្តមាន ទ័ព យៀកកុង នៅ កម្ពុជា, សម្តេច សីហនុ ព្រះអង្គ ព្រម ទទួល ថា ជាការពិត ហើយ ព្រះអង្គ បាន អនុញ្ញាត ៤ កង ទ័ពអាមេរិកាំង ធ្វើប្រតិបត្តិសឹក ទ្រង់ទ្រាយតូច នៅ តាម ដំបន់ ដាច់ស្រយាល ក្នុងទឹកដីខ្មែរ ដ៏រាបណា សកម្មភាព ទាំងនោះ មាន កំរិតតិចតួច មែនទែន។ នៅ ថ្ងៃ ទី ២ មេសា ឆ្នាំ ១៩៦៩ ក្នុងនយោបាយ រកការទំនាក់ទំនងជាថ្មី រវាង ស.រ.អ. ជាមួយកម្ពុជា លោក ប្រធានាធិបតិ Richard M. Nixon បានប្រកាស ជា ឧឡារិក ទទួល ស្គាល់ នូវ អធិបតេយ្យភាព ឯករាជភាព អព្យាក្រឹតភាព និង បូរណភាពទឹកដី នៃ រាជាណាចក្រ កម្ពុជា។ ផ្ទុយទៅវិញ

កងកម្លាំង កុម្មុយនិស្តយួនបានចូលមក កាន់កាប់ ប្រមាណ ១ ភាគ ៣ នៃទឹកដីខ្មែរ។ ដើម្បី ទប់ទល់ នៃ ការ វាតទី នេះ លោក Richard M. Nixon បាន អនុញ្ញាត ឲកង ទ័ពអាកាស ស.រ.អ. ទម្លាក់ គ្រាប់បែក ដោយ សំងាត់ ក្នុង ស្រុកខ្មែរ នៅក្នុង ទីដំបន់ណា ដែល មាន មូលដ្ឋាន ទ័ព កុម្មុយនិស្តយួន។ ប្រតិបត្តិការសឹក នេះ មាន ឈ្មោះ ថា « Menu »។ នៅ ឆ្នាំ១៩៦៩ នេះ ដែរ កម្ពុជា និង ស.រ.អ. មាន ការទំនាក់ទំនង តាមផ្លូវទូត ឡើងវិញ ហើយ ស្ថាន ទូត ស.រ.អ. ចាប់ ផ្តើម បើកទ្វារ នៅ កម្ពុជា ក្នុងថ្ងៃទី ១៦ សីហា។ តែ ស.រ.អ. ក៏ ចាប់ ផ្តើម អនុវត្ត ផែនការ ដកទ័ព ខ្លួន ចេញពីយៀកណាមដែរ ដោយសារ ជនជាតិ អាមេរិកាំង ដែល ជា អ្នកប្រឆាំងនឹង សង្គ្រាម នៅយៀកណាម កាន់តែកើត ចំនួនច្រើនឡើងៗ ព្រោះ សង្គ្រាមនេះ កាន់តែបង្ហាញ នូវ រូបភាពអាសគ្រាម ផ្សាយតាម កញ្ចក់ ទូរទស្សន៍ នៅ ស.រ.អ. និង នៅ បស្ចឹមប្រទេស ដែលនាំឲ មតិ សាធារណជន ក្នុង ពិភពលោក ផ្តន្ទាទោស ហើយជា ពិសេស នៅ ស.រ.អ. យុវជន នាំគ្នាធ្វើបាតុកម្ម ប្រឆាំង នឹង សង្គ្រាម នៅយៀកណាម។

មកដល់ទីនេះ យើងគួរ លើក យក គោលដៅ របស់ យួន កុម្មុយនិស្ត មកសិក្សា ដោយសួរជា សំណួរ ថា តើ ពួកគេ ចង់បានអ្វី ?

ចមគោលដៅ របស់យួនបក្សកុម្មុយនិស្ត គឺ ឯកភាពយៀកណាម។ យួនគេទុកជ័យជំនះ របស់ គេ លើ កងទ័ពបារាំង នៅ ក្នុង ឆ្នាំ ១៩៥៤ ជា ជ័យជំនះ មិនពេញលេញ ព្រោះ យៀកណាម ត្រូវបាន កាត់ចែក ជា ពីរ ចំណែក : ខាងត្បូង ជា យៀកណាមសេរី ខាងជើង ជា យៀកណាមកុម្មុយនិស្ត។ ដូច្នេះ បក្សកុម្មុយនិស្តយួន គេយល់ឃើញថា គេ ត្រូវមានករណីយកិច្ច បន្ត សង្គ្រាម ដើម្បី បង្រួបបង្រួម យៀកណាម ឲមានតែមួយ។ នៅក្នុង ចមគោលដៅ នោះ បក្សកុម្មុយនិស្តយួន គេមាន គោលបំណងសំខាន់ ពីរទៀត ដែល ជាគោលបំណង របស់ អ្នកដឹងនាំយួន តាំង ពី សម័យដើមមក៖ ១. គឺ វិជ្ជមានកម្ម នៃ ឯករាជ្យ នៃប្រជាជាតិយៀកណាម ទល់មុខនឹង ប្រទេស ចិន ; ២. គឺ តាំងពី សតវត្ស ទី១៦ មក អ្នកដឹកនាំយួន តែងតែមាន មហិច្ឆតាខ្វាប់ខ្ជួន ស្រូបយក ប្រទេស ខ្មែរ បញ្ចូលទៅ ក្នុង ប្រទេសយួន។ តែដោយសារមានអន្តរាគមន៍ ស.រ.អ. នៅយៀកណាមខាងត្បូង ប្រឆាំងនឹង លទ្ធិកុម្មុយនិស្ត តាមផ្លូវនយោបាយ និង មធ្យោបាយយោធា នាំឲបក្សកុម្មុយនិស្តយួន ប្រមូលផ្តុំ ថាមពល ខ្លួន ធ្វើ សង្គ្រាមឲ ឈ្នះ ស.រ.អ. សិន។ ដូច្នេះចម្បាំងប្រឆាំងនឹង អាមេរិកាំង គ្រាន់ជា ដំណាក់ អន្តរកាល ដើរ ឆ្ពោះទៅ ទៅរក មហិច្ឆតា ពាន់ឆ្នាំ របស់ ប្រជាជាតិយួន។ នៅចំពោះមុខ មហាអំណាច ពិភពលោក, បក្សកុម្មុយនិស្តយួន ដើរ តួខ្លួន ជា

អ្នករងគ្រោះផង និង ជា អ្នកតស៊ូ មិនចុះចាញ់ផង ហើយ ប្រើគ្រប់ កលល្បិច និង សម្ព័ចូ (កលល្បិចលាក់មុខ) ដើម្បី ធ្វើ ឲ សៈរៈអៈ អប្បយស ក្លាយជា ប្រទេសចក្រពត្តិនិយម ឈ្លានពានប្រទេសទន់ខ្សោយ ដើម្បី ដាក់ ជា ប្រទេស អាណានិគម របស់ខ្លួន។ ក្នុង សម្ព័ចូ នេះ បក្ស កុម្មុយ និស្តយួន ទទួល បាន ជោគជ័យ ដូចបំណងខ្លួន គឺថា អាច រុញច្រាន កងទ័ព អាមេរិកាំង ឲចេញ ពី ប្រទេស យៀកណាម បានដោយ មិនបាច់ ឈ្នះ សង្គ្រាម។ ជ័យជំនះ នេះ ជាជ័យជំនះ ពេញលេញ ដែល អាចឲអ្នកដឹកនាំយៀ កណាម បន្ត កលល្បិច ដើម្បី ធ្វើ ឲ សម្រេច នូវ គោល បំណង នៃ មហិច្ឆិតា របស់ បុព្វបុរសខ្លួន គឺ ស្រូបយក ប្រទេសខ្មែរ និង លាវ បញ្ចូល ក្នុង ប្រទេស យៀកណាម ដើម្បី ឲ ក្លាយ ទៅ ជា មហាយៀកណាម មាន ឯករាជ្យ បរិបូរណ៍ នៅ ចំពោះមុខ មហាប្រទេសចិន។

យើងឃើញថា សង្គ្រាម នៅយៀកណាម មិនមែនជា បុព្វ ហេតុសំខាន់ នៃ សង្គ្រាម កើតមាន នៅ ស្រុកខ្មែរ ក្នុង ឆ្នាំ ១៩៧០ នោះ ទេ។ បុព្វហេតុ ពិត គឺ មហិច្ឆតា របស់បក្ស កុម្មុយនិស្តយួន ប្រើ គ្រប់ កលល្បិច ផ្តាច់ កម្ពុជា ឲនៅឯ កោ ក្នុងយុទ្ធសាស្ត្រ សៈរៈអ ប្រឆាំង កុម្មុយនិស្ត នៅ ឥណ្ឌូ ចិន។ ភាពឯកោ នេះ ធ្វើឲ ស្រុកខ្មែរ គ្មាន មធ្យោបាយ គ្រប់គ្រាន់ ដើម្បី ការពារខ្លួនឯង រាល់ការគំរាមកំហែង មកលើខ្លួន។ ស្រុកខ្មែរ ក្លាយជារំពា សំរាប់ យៀកណាម

ចាប់ស៊ី ងាយ ស្រួល បំផុត នៅ ពេលណា ដែល គេ អាច ចាប់ស៊ី។ ដូច្នេះ អ្វីដែលនឹងអាចកើតឡើងបាន វាបាន កើតឡើងមែននៅឆ្នាំ ១៩៧០។

## សង្គ្រាម គ្មានប្រកាស

នៅថ្ងៃទី ២៧ មីនា ឆ្នាំ ១៩៧០ កងទ័ពយៀកកុង បើកការវាយប្រហារ មកលើ កងទ័ពជាតិខ្មែរ ដោយគ្មានប្រកាសជាមុន។ ពួកនោះ ក្លែងខ្លួន ជាទ័ពខ្មែរ សីហនុនិយម ភេរវាស្ត្រខ្មែរថា ច្បាំងប្រឆាំងនឹង កងទ័ពក្បត់ជាតិ ដែលពួកគេហៅថា បន លន់នល់ ដើម្បី យកអំណាចមកថ្វាយសម្តេចឱ្យវិញ[2]។ ពួកយៀងកុង វាយបន្ទាយខ្មែរ នៅ ស្នួល, មេមុត, ក្រែក, ស្អាង, កោះធំ, កំពង់ត្រាច, ទីក្រុងស្ទឹងត្រែង និង ក្រចេះ ហើយ កាន់កាប់បាន ខេត្ត ៤ : ស្ទឹងត្រែង, ក្រចេះ, រតនគិរី និង មណ្ឌលគិរី ដែលពួកគេ បានមកបោះទ័ព នៅទីនោះតាំងពីឆ្នាំ ១៩៦២ មកម្លេះ។ ហើយ នៅក្នុងខេត្តទាំងបួននោះ មានទាហ៊ានខ្មែរនៅការពារតិចតួចណាស់ ព្រោះនយោបាយ សម្តេច សីហនុ នៅពេលនោះ គឺ ទ្រង់ យកទាហ៊ាន មកប្រើក្នុងកិច្ចការ មិនមែន យោធា ដូចយ៉ាង សង់ ស្ពាន, ផ្លូវ ។ល។ ដែល

[2] សម្តេច សីហនុ ក្រោយពីធ្លាក់ដំណែង ទ្រង់ យាងទៅស្រុកចិនកុម្មុយនិស្ត ហើយនៅទីនោះ ទ្រង់ បង្កើត រណសិរ្ស បង្រួបបង្រួមជាតិខ្មែរ និង រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិខ្មែរ នៅថ្ងៃទី ២៤ មីនា ១៩៧០។

នាំឲកងទ័ព បាត់ នូវសមត្ថកិច្ចមូលដ្ឋាន របស់ខ្លួន។ នៅខែ មិថុនា នៅចំពោះមុខ ការវាយប្រហារ ផ្តេកភ្លាមនេះ និង កង្វះ នៃមធ្យោបាយការពារ, អគ្គបញ្ជាការ ជាន់ខ្ពស់ នៃ កងទ័ពជាតិខ្មែរ បានសម្រេច ដក កងយោធភូមិ (garnisons) ទាំងឡាយ ចេញពីដំបន់ ព្លសាន ហើយ បាន រៀបចំ ខ្សែក្រវាត់ការពារ បរិវេណ នៃ យាមកាម មួយ ដើម្បី ពង្រឹង កងទ័ពជាតិ, អង្គការនយោបាយ និង ការពារសុវត្ថិភាព នៃ ប្រជាពលរដ្ឋ។ ខ្សែការពារនោះ គេឲឈ្មោះ ថា បន្ទាត់ទប់ទល់ របស់លន់នល់ ដែល ជា បន្ទាត់ កលយុទ្ធ។ បន្ទាត់នេះ ចែកផ្ទៃដីស្រុកខ្មែរ ជា ពីរដំបន់៖ ដំបន់ខាងជើង និង ខាងត្បូង។ ខាងជើងជា សមរភូមិ ក្តៅ ដែល មាន វត្តមាន ទ័ពយៀកកុង ឯចំណែក ខាង ត្បូង ជា ដំបន់កាន់កាប់ ដោយ កងទ័ពជាតិខ្មែរ។ បន្ទាត់ នេះ មាន បណ្តោយ ពី ព្រំប្រទល់ ខ្មែរ-សៀម ចេញពី ស្រុក អូស្មាច់ ក្នុងខេត្ត ឧត្តមានជ័យ កាត់ អង្គរវត្ត ក្នុង ខេត្ត សៀមរាប បន្តទៅស្រុក មេមុត ក្នុង ខេត្តកំពង់ចាម ចាក់រហូត ទៅដល់ ទល់ដែន ខ្មែរ-យៀកណាមខាងត្បូង។ បន្ទាត់នេះ នៅ ស្របតាម ផ្លូវជាតិ លេខ៦ និង ៧ ដែល ជា រោហិណី សំខាន់ សំរាប់ ជីវិត សេដ្ឋកិច្ចខ្មែរ។

មកដល់ខែ មិថុនា ទស្សនវិស័យ នៃ ជ័យជំនះ រហ័ស របស់ យៀកកុង កាត់តែបញ្ចៀសពី ការនឹកស្មាន របស់ ពួកវា រហូត ចាត់ទុក ថា មិនអាចមាន តែម្តង។ កងទ័ពជាតិ

ខ្មែរ រឹតតែមានសេចក្ដីទុកចិត្ត លើសក្ដានុភាពរបស់ខ្លួន។ ចំនួនយោធា កាន់តែកើតឡើង ដោយសារ មាន យុវជន រាប់ម៉ឺននាក់ ស្ម័គ្រចិត្តចូលធ្វើទាហ៊ាន។ ពីចំនួន ៣ម៉ឺន នាក់ ទៅ ២សែនកន្លះ។ ដូច្នេះ តម្រូវ ឲមាន ការរៀបចំ ច្បាស់លាស់ និង ការហ្វឹកហ្វឺន ប្រកប ដោយ គុណភាព ដែល ជា ការធានា នៃ ជីវិត យោធា តែមួយគត់ នៅក្នុង សមរភូមិ។ ដោយសារ ពួកយៀកកុង យកផ្ទៃដីខ្មែរ ជា សមរភូមិ នៃ សង្គ្រាម ទាំងអស់ (la guerre totale), រដ្ឋាភិបាលខ្មែរ ត្រូវចាំបាច់ បញ្ជូន យោធាខ្មែរ ទៅហ្វឹកហ្វឺនក្បួនសឹក នៅក្នុង មជ្ឈមណ្ឌលហ្វឹកហ្វឺន យោធា របស់ អាមេរិកាំង នៅ យៀកណាមខាងត្បូង និង នៅ ប្រទេសសៀម។ អគ្គបញ្ជាការខ្មែរ ចាត់ការរៀបចាំ កងឯកភាព យោធា ជាថ្មី បង្កើត កងពលតូច និង កងពលធំ ដើម្បី ទប់ទល់ នឹងកងពលធំ របស់សត្រូវប្រដាប់ អាវុធយុទ្ធភ័ណ្ឌទំនើប។ ស្ថានភាព នៅស្រុកខ្មែរ នៅពេលនោះ វា ដូច ជា ឃ្លាមួយ របស់ អ្នកនិពន្ធ បរទេស ម្នាក់ ឈ្មោះ Alberti សរសេរ ថា៖ ‹ *យើង មិនទាន់ដឹងច្បាស់ ថា តើ ទិសណាមួយ ដែល យើង នឹងអណ្ដែត រសាត់ ទៅនោះឡើយ នៅកណ្ដាល មហាសាគរ ប៉ុន្តែ ហាក់បី យើង មាន អារម្មណ៍ ពិសម័យ រួចហើយ នៅ ពេល ក្បាលយើង ងើបផុត ពី ក្នុងទឹក ដែល អាច ឲយើង ដកដង្ហើម បាន*›។

នៅក្នុងទស្សនៈនេះឯង ដែលលោក លន់ នល់ គាត់ បើក ប្រតិបត្តិការសឹក ចេនឡា ដើម្បី បង្ហាញដល់ខ្មាំងជាតិថា កងទ័ពខ្មែរ មិនគ្រាន់តែមាន សមត្ថភាព ចេះការពារ ខ្លួន តែក៏អាចមានលទ្ធភាព វាយលុកខ្មាំង ដើម្បី រំដោះទឹក ដីផងដែរ។

## ប្រតិបត្តិការសឹក ចេនឡា

ការជ្រើសរើស ឈ្មោះ នៃ ប្រតិបត្តិការសឹកនោះ ជា ទស្សមានាការ (phase) មួយ សំខាន់ ដើម្បី បញ្ជាក់ នូវ គំនិត និង មហិច្ឆតា នៃ បេសកកម្មសឹក។ សព លោក កេង វ៉ាន់សាក់ ប្រហែល ជា អ្នក ណែនាំ ឲ លោក លន់ នល់ ជ្រើសរើស ឈ្មោះ ប្រតិបត្តិការសឹកនេះ ព្រោះ កាល លោក នៅ មាន ជីវិត លោក ធ្លាប់ថ្លែងថា ចេនឡា នេះ មានន័យ ថា ជា ដំណើរ ស្វែងរក ឯកភាព ជាតិខ្មែរ ដោយ ប្រើ កម្លាំងខ្មែរ តែ លោក មិនព្រម បញ្ជាក់ ហើយ ក៏ មិនបដិសេធដែរ ថា លោក ជា អ្នកដើមគំនិត នៃ ឈ្មោះនេះ។ ត្រូវដឹង ថា សព លោក កេង វ៉ាន់សាក់ លោក មាន ឥទ្ធិពល លើ លោក លន់ នល់ ច្រើនណាស់ នៅ ក្នុង វិស័យ វប្បធម៌ខ្មែរ។

### ១. គោលដៅ

គោលដៅ គឺ រំដោះស្រុក កំពង់ថ្ម ដែល ជា ទ្វារ ដើរចូល ក្រុង កំពង់ធំ តាម ផ្លូវជាតិ លេខ៦ ដែល ពួក យៀកកុង

ព័ទ្ធ ជុំវិញ តាំង ពីផ្តើម សង្គ្រាម មកម្លេះ។ ជាពិសេស ការកាន់កាប់ ផ្លូវជាតិ លេខ៦ គឺ អាច កាន់កាប់ ដំបន់ មជ្ឈិម ដែល ជា ជម្រុក ស្រូវ ធំមួយ នៅ ស្រុកខ្មែរ។ តែ ចេនឡាចំពោះ លោក លន់ នល់ ក៏ មាន គោលដៅ នយោបាយបន្ថែម ក្នុង យុទ្ធសាស្ត្រយោធា ដែរ គឺ បង្ហាញ នូវ សម្ថភាព របស់លោកជា អ្នកដឹកនាំ ជាតិខ្មែរ ក្នុង វិស័យយោធា និង នយោបាយ។

**១. រណវង្គយោធា (théâtre d'opération militaire)**

រណវង្គយោធា គឺ ស្រុក ស្គុន, កំពង់ថ្ម និង ទ្រើង។ លោក ឧត្តសេនីយ ត្រី អ៊ុំ-សវុធ ជា មេបញ្ជាការ នៃ ប្រតិបត្តិការសឹក មាន បញ្ជាការដ្ឋាន និង មូលដ្ឋាន ភស្តុភា នៅ ក្រុងស្គុន។ ចំនួនទ័ព មាន ១២ កង វរសេនាតូច, កង រថក្រោះ និង កាំភ្លើងធំ។ លោក អ៊ុំ សវុធ ធ្លាប់ បាន បញ្ចេញ ស្នាដៃ នៅ លើ សមរភូមិ ជា ច្រើន ចាប់ ពី សង្គ្រាម ផ្ទុះឡើង ហើយ មាន កេរ៌ ឈ្មោះ ជា មេទ័ព អបរាជ័យ។ ជំនាន់ សម្តេច សីហនុ លោក ជា នាយទាហ៊ាន ជាន់ខ្ពស់ខ្មែរ មួយរូប ទទួល បេសសកម្ម ពិសេស ពី ព្រះប្រមុខរដ្ឋ ផ្ទាល់ ធ្វើការទំនាក់ទំនង ជា សម្ងាត់ ជាមួយ ពួក យៀកកុង តាំងទ័ព នៅ ក្នុង ទឹកដីខ្មែរ។ ក្នុង គុណភាព ទាំងឡាយនេះ ហើយ ដែល លោក លន់ នល់ ប្រគល់ មេបញ្ជាការសឹក លើក ដំបូង បង្អស់ ដ៏ វិសេសវិសាល មួយ គឺ ការវាយលុក

ខ្មាំង រំដោះ ទឹកដី ខ្មែរ។ ដូច្នេះ ការរំដោះ ទឹកដី ដោយ យក ឈ្មោះ ចេនឡា ជា ការប្រាថ្នា នៃ ជោគជ័យ មិនមែនដូច ការរិះគន់ ពី សំណាក់ អ្នកសារពត៌មាន អន្តរជាតិខ្លះ ថា ប្រតិបត្តការសឹក នេះ ធ្វើឡើង សំរាប់ បំរើប្រយោជន៍ នយោបាយ ច្រើនជាង យុទ្ធសាស្ត្រយោធា ហើយ យក ឈ្មោះ ប្រកប ដោយ មហិទ្ធានុភាព (ឈ្មោះ នៃ មហា នគរ ខ្មែរ ៥៥០-៨០២) ដើម្បី បង្ហាញ កិត្យានុភាព នៃ សាធារណ រដ្ឋខ្មែរ ថា ជា ទាយាទ (héritier) ជម្នានុរូប នៃ មហា នគរ ខ្មែរ។

កងទ័ពខ្មែរ បើកក្បួនទ័ព ជា ពីរ ជួរៈ ជួរទី ដើរចេញ ពី ស្រុក ស្អួន សំដៅទៅស្រុក កំពង់ថ្ម ត្រូវ ឆ្លងកាត់ ស្រុកបី : ប្រាខម, តាំងគោក និង បារ៉ាយ។ ជួរទីពីរ ដើរចេញ ពី ស្រុកទ្រើង សំដៅ ទៅ កំពង់ថ្ម ឆ្លងកាន់ ស្រុក ពីរ : បូស ខ្នោ និង ចំការអណ្តូង។ ក្នុងខែ កញ្ញា ជួរទី១ វាយខ្មាំង រំដោះ បាន ស្រុក តាំគោក និង ប្រជាពលរដ្ឋ ជាច្រើន ដែល រស់នៅ ក្នុងដំបន់ ខ្មាំងកាន់កាប់។ រីឯ ជួរទី២ វិញ បាន ជួបប្រទះ ប្រយុទ្ធ ជាមួយ កង ឯកភាព តូចៗខ្លះ នៃ កងពលធំ លេខទី៩ តាំងទ័ព នៅ ចំការកៅស៊ូ អណ្តូង[3] ក្បែរ ខាងលិច នៃ ផ្លូវជាតិ លេខ៦ របស់ ខ្មាំង នៅ បូសខ្នោ តែ កង ឯកភាព ខ្មាំង ដកថយ ចេញពី សមរ

[3] កងទ័ពខ្មែរ ឥតបានដឹងថានៅ ចំការអណ្តូង ជាទីតាំងទ័ពធំ របស់ខ្មាំង យួននោះឡើយ។

ភូមិ ព្រោះ មិនចង់ ឲ យន្តហោះ សំគាល់ ទីតាំង ទ័ព របស់ ខ្លួន។

នៅ ក្នុង ខែ វិច្ឆិកា និង ធ្នូ ឆ្នាំ ១៩៧០ មួយខែក្រោយ ពី ធ្វើការប្រកាស បង្កើត សាធារណរដ្ឋខ្មែរ (៩ តុលា ឆ្នាំ ១៩៧០) ពួកយៀកកុង ហាក់បីមិនសូវរវល់ ទប់ទល់នឹង ការវាយលុក នៃប្រតិបត្តិការសឹក ចេនឡា នោះទេ, តែ បែរ ជា វាយ ទីតាំង ទ័ពខ្មែរ នៅតាម ផ្លូវជាតិ លេខ៧ នៅ ចន្លោះ ស្រុក ព្រៃទទឹង និង ទីក្រុង កំពង់ចាម ក្នុងគោល ដៅ វាយចូល កាន់កាប់ ទីក្រុង កំពង់ចាម តែម្តង។ ប្រតិបត្តិការសឹក របស់ ពួកយៀកកុង នេះ គឺជា ចម្លើយ តបនឹង ប្រតិបត្តិសឹក ចេនឡា ផង និង ចូល មកតាំងទី នៅក្នុង ខ្សែ ការពារ បរិវេណ សុវត្ថិភាព នៅក្នុង ខ្សែ បន្ទាត់ ទប់ទល់ លន់នល់ ផង។ នៅពេលជាមួយគ្នា នោះ ដែរ កង ឯកភាព យៀកកុង មក ពី យួនខាងត្បូង ចូល មក ក្នុង ស្រុកខ្មែរ ដើម្បី ទទួល បេសកកម្មពិសេស វាយ កាត់ផ្តាច់ ផ្លូវជាតិ លេខ៤ (ភ្នំពេញ-កំពង់សោម)។ នៅ ក្នុងខែ មករា ឆ្នាំ ១៩៧១ ក្នុង រាត្រី ថ្ងៃទី ២១ និង ២២ កង កុម្ម៉ង់ដូ យៀកកុង មាន ចំនួន ១០០ នាក់ លួច ចូលបាន មក វាយ ចំណត អាកាសយាន យន្តហោះ ពោធិចិនតុង និង មូលដ្ឋាន កងទ័ព អាកាសខ្មែរ កំទេច យន្តហោះ ស៊ីវិល និង យោធា ស្ទើតែទាំងអស់។ យើងឃើញថា ពីរខែ បន្ទាប់ ពី ប្រតិបត្តិការសឹក ចេនឡា យួនកុម្មុយនិស្ត ធ្វើ

ការវាយសម្រុក នៅក្នុង រណរង្គយោធា ដ៏ ធំ ទូលាយ មួយ នៅក្នុងបរិវេណ ការពារខ្មែរ ដើម្បី សម្រេញ ទ័ពខ្មែរ មិនឲ អាចនឹង ប្រមូលផ្តុំ កម្លាំង ធ្វើប្រតិបត្តិការសឹក វាយលុក បាន និង កាត់ផ្តាច់ផ្លូវ ដឹកស្បៀង គឺ ផ្លូវជាតិ លេខ៤ ពី កំពង់ ផែ កំពង់សោម មក ទីក្រុង ភ្នំពេញ។ នៅចំពោះ មុខ ការវាយប្រហារ ធំទូលាយ របស់យួនកុម្មុយនិស្តនោះ តម្រូវឲ អគ្គបញ្ជាការ នៃយោពលខេមរជាតិ ដក ច្រើន កងវរសេនាតូច ចេញពី សមរភូមិ ចេនឡា ដើម្បី យក មកការពារ ទីក្រុងភ្នំពេញ។ ស្ថានភាពសឹកគួរឲបារម្ភនោះ រដ្ឋសភាជាតិ បានអញ្ជើញ លោក លន់ នល់ ឲមកពន្យល់ អំពី យុទ្ធសាស្ត្រ នៃការពារជាតិ របស់លោក ក្នុង ឋានៈ ជា អគ្គមេបញ្ជាការ នៃកងទ័ពជាតិ។ ថ្ងៃដែលគ្រងទុក នៃ ជំនួបនោះ គឺ ៨ កុម្ភៈ ឆ្នាំ ១៩៧១។ តែនៅក្នុងរាត្រី ទី៧ កុម្ភៈ លោក លន់ នល់ មានជម្ងឺ ខ្វិនជើង (paraplégie) តម្រូវ ដឹកលោកជាប្រញាប់[4] ទៅព្យាបាល នៅមន្ទីពេទ្យ នៅទីក្រុង Honolulu ក្នុងទឹកដី សហរដ្ឋអាមេរិក។ ប្រតិបត្តិការ ចេនឡា ត្រូវបានផ្អាកមួយរយៈ ចាប់ពីពេល នោះមក។

នៅថ្ងៃទី ១២ មេសា ឆ្នាំ ១៩៧១, លោក លន់ នល់ បានវិល ត្រឡប់មកស្រុកខ្មែរវិញ។ ជាបឋម លោក ចាប់ផ្តើមបើក ប្រតិបត្តិការសឹក ចេនឡា ឡើងវិញ ដោយឲឈ្មោះថា ចេន

[4] ថ្ងៃទី ១៤ កុម្ភៈ ឆ្នាំ ១៩៧១។

ឡាទី២។ ឈ្មោះកូដនៃប្រតិបត្តិការ គឺ ‹ភ្នែកទល់នឹងភ្នែក, ធ្មេញទល់នឹងធ្មេញ, ឈាមទល់នឹងឈាម›។ មេបញ្ជាការសឹក គឺ ឧត្តមសេនីយ ហូ ហង់ស៊ីន។
ថ្ងៃទី ២៦ សីហា ឆ្នាំ ១៩៧១ កងទ័ពជាតិខ្មែរ វាយយកស្រុកបារាយណ៍ បាន ហើយ នៅថ្ងៃទី២ កញ្ញា កងពលតូច លេខ ៥ (brigade) ចាប់ផ្តើមវាយយកភ្នំសន្ទុក។ តែទ័ពយួនកុម្មុយនិស្តនៅទីនោះ ទប់ទល់យ៉ាងខ្លាំងក្លាបំផុត។ តែនៅថ្ងៃទី ២០ កញ្ញា ខ្មែររំដោះបាន ស្រុក តាំងក្រសាំង។ នៅចពោះមុខការទប់ទល់ដ៏ខ្លាំងក្លា នៃទ័ពយួន នៅថ្ងៃទី ៥ តុលា ទ័ពខ្មែរ បានបន្ថែម ៣ កងពលតូច ក្នុងសមរភូមិ ភ្នំសន្ទុក ដើម្បីវាយទីតាំងយួន តែវាយមិនបែក។ រហូតដល់ថ្ងៃទី ២៥ តុលា ខ្មែរ ដូរទិសវាយប្រហារ ដោយដឹកកងពលតូច លេខ២៨ តាមឧទ្ធម្ភាចក្រ វាយសម្រុកផ្លែកភ្លាម តាមទិសអាគ្នេយ៍ ដែលទុកជាចំណុចការពារខ្សោយរបស់ខ្មាំង។ ការប្រយុទ្ធគ្នា នៅពេលនោះ មាន ខ្លួនទល់នឹងខ្លួន រហូតដល់ទទួលបានជ័យជំនះ រំដោះភ្នំសន្ទុកបាន ដែលជាបូជនីយដ្ឋាន របស់ខ្មែរ។ ជោគជ័យនេះ ទ័ពខ្មែរ បានបើកផ្លូវជាតិ លេខ៦ បាន រហូតដល់ ក្រុងកំពង់ធំ។ ដំណាក់កាល ប្រតិបត្តិការសឹក ចេនឡា ទី២ ក៏អាចចាតើទុកថាចប់។ រដ្ឋាភិបាលខ្មែរ បានធ្វើបុណ្យជោគជ័យនោះ ចំនួនបីថ្ងៃ។ ឧត្តមសេនីយ អ៊ីត សួង មេបញ្ជាការកងពលតូចមួយ ក្នុងចំណោម កងពលតូច

ទាំងឡាយ បានមករៀបរាប់ ដោយរីលរាយ អំពីស្ថានការទ័ព ក្នុងសមរភូមិ ឈានឬទ្ធិខ្មែរ។
តែនៅយប់ថ្ងៃទី៣ នៃបុណ្យជោគជ័យនោះ ទព័យួន វៃគប់គ្រប់ទីតាំងទ័ពខ្មែរ តាមផ្លូវជាតិ លេខ៦។ កងពលធំលេខ ៩ និង កងភូមិភាគ លេខ ២០៥ និង ២០៧ នៃកងទ័បយួនខាងជើង ដែលមានទីតាំងទ័ពនៅ ចំការអណ្ដូង បានវាយប្រហារ ទីតាំង នៃកងវរសេនាតូចខ្មែរ លេខ ៣៧៦ នៅក្រៀល ស្ថិននៅ រវាងស្រុក តាំងគោក និង រំលោង។ តែមួយ ស្របក់ កងទ័ពខ្មែរ បានរលាយសូន្យ នៅសល់តែទាហ៊ាន ចំនួន ប្រមាណ ២០នាក់ រត់រួចមកដល់ស្រុកបារាយណ៍។ ការវាយប្រហារផ្ដេកភ្លាមនោះ នាំឲខ្មាំង ព័ទ្ធស្រុករំលោង បានភ្លាម។ នៅទីនោះ មាន កងវរសេនាតូច លេខ១១៤ សំរាប់ការពារ ស្ពៀនដែក និង ទីបញ្ជាការ នៃកងពលតូច លេខ៤៦ ហើយមាន ផ្នែកកាំភ្លើង ១០៥ មម មួយកងតូចផង។
នៅរាត្រី ថ្ងៃទី២៨ តុលា ទីតាំងទ័ពខ្មែរ នៅ ដំរីស្លាប់ ទទួលការវាយប្រហារ ដោយគ្រាប់បែកគីមី (gaz shells) បង្ខំឲខ្មែរដកទ័ពថយ មក ភូមិគ្រឿល។ នៅទីនោះ ការពារដោយ កងវរសេនាតូច លេខ ១១៨ និង កងវរសេនាតូច លេខ២១១។ តែបន្ទាប់ភ្លាមមក គឺនៅពេលព្រលឹមថ្ងៃទី២៩ ទីតាំងនោះ ត្រូវពួកយួន វាយយ៉ាងខ្លាំង។ មេបញ្ជាការខ្មែរ សម្រេច ដកទ័ពថយ មកនៅ ស្រុកតាំងគោក។

នៅចំពោះមុខ ការវាយប្រហារជាទូទៅនេះ, ឧត្តមសេនីយ ហូ ហង់ស៊ីន មេបញ្ជាការ ប្រតិបត្តិការសឹក ចេនឡាទី២ បានរៀបចំជាថ្មី នូវយុទ្ធសាស្ត្រ ការពារ។ លោក បញ្ជាឲ កងពលតូច លេខ៦១ និង កងវរសេនាតូច លេខ៤២៤ នៃកងពលតូច លេខ៦២ តាំងនៅភូមិគីរី ដកមក ភូមិ ត្រៀល ជាប្រញាប់។ ហើយ កងវរសេនាតូច លេខ២២២ និង ៣៧៧ តាំងនៅ ភូមិនាក់រៀង ដកមក រូមការពារ ស្រុកតាំងគោក។ ពីថ្ងៃទី ២៨ ដល់ ៣១ តុលា ទហ៊ានខ្មែរ ស្លាប់នៅក្នុងសមរភូមិ ប្រមាណ ១០០នាក់ ក្នុងមួយថ្ងៃ ហើយមាន អ្នករបួស ជាច្រើនទៀត។ ដោយសារ ខ្វះ ឧទ្ធម្ភាចក្រ ដឹកអ្នករបួសជូន់ មកកាន់មន្ទីរពេទ្យ និង គិនុប្ដយោធា ខ្វះមធ្យោបាយគ្រប់គ្រាន់ ដើម្បី ព្យាបាលរបួស, ទាហ៊ានរបួសទាំងឡាយនោះ បានត្រូវបាត់បង់ជីវិតទៅ។

នោះបីមានការវាយប្រហារយ៉ាងខ្លាំង ពីសំណាក់យួន តែ ទ័ពខ្មែរ វែតបរិញ ជាបន្ទាន់ ដើម្បី បង្កើត ខ្សែក្រវាត់ ការពារជីវិតមួយ ឋិតនៅរវាង ភូមិស្វាយ និង ស្រុករំលោង ព្រោះស្ទើគ្រប់ទីតាំងទ័ពខ្មែរ ត្រូវខ្មាំងព័ទ្ធជាប់ ឬ ទឹកលិច ជុំវិញ។ ស្ថានភាពបែបនោះ នាំឲទ័ពខ្មែរពិបាកនឹង វៃតប ខ្មាំង ហើយ ធាតុអាកាសមិនល្អ គឺថាមានភ្លៀងច្រើន ធ្វើឲទ័ពអាកាស ពិបាកធ្វើ អន្តរគមន៍ឲបានស័ក្តិសិទ្ធ ថែមទៀត។ ទាហ៊ានខ្មែរ នៅលើសមរភូមិជាច្រើន ត្រូវ ខ្មាំងឡោមព័ទ្ធ ជាច្រើនថ្ងៃ ចាប់អស់កម្លាំងណាស់ តែ

ទឹកចិត្ត នៅមានសេចក្ដីក្លាហានជានិច្ច ដើម្បី សត៊ូ វាយខ្លាំង។ តែ កង្វះ ស្បៀងអាហារ និង គ្រាប់រំសេវ ពិបាកនឹងរក្សាបានយូរអង្វែង នូវកម្លាំងទឹកចិត្ត។ ដូយ៉ាង កងយោភូមិខ្មែរ ប្រចាំ ស្រុករំឡួង និង ត្រៀល អស់គ្រាប់រំសេវ ដើម្បីទប់ទល់ខ្លាំង ក៏សម្រេចចិត្ត ដាក់អាវុធ។

នៅពេលដែលខ្លាំងយួន វាយទ័ពខ្មែរ គ្រប់ទីតាំង, មាន ទាហ៊ានខ្លាំងយួន ជ្រាតចូលបាន ក្នុងជួរទ័ពខ្មែរ ធ្វើវិទ្ធស្សនា បង្កើតឲមានព្យាកុលភាព។ ហើយឆ្លៀតឱកាស ក្លែងបន្លំសុំអន្ដរគមន៏ ពីទ័ពអាកាសខ្មែរ ឲទំលាក់គ្រាប់បែក មកលើទីតាំងទ័ពខ្មែរគ្នាឯង នាំឲស្លាប់ទាហ៊ានជាច្រើន។ តែក្រោយបន្ដិចមក ទ័ពខ្មែរ អាចបង្កើតខ្សែបន្ទាត់ការពារមួយបាន នៅខាងជើងស្រុកបារាយណ៏។ តែទោះបី មានជំនួយពីទ័ពអាកាស, ទ័ពខ្មែរ គ្មានលទ្ធភាពនឹងវាយយកទីតាំង ដែលខ្លាំង វាយយកបាន នោះឡើយ ជាពិសេសអាចបន្ថយ កម្លាំងកាំភ្លើងធំខ្លាំង បាញ់ចេញ យ៉ាងខ្លាំង ពី ចំការអណ្ដូង។ រហូតដល់ថ្ងៃទី ១៤ វិច្ឆិកា ទ័ពអាកាសអាមេរិកាំង បានធ្វើអន្ដរគមន៏ ជួយទ័ពខ្មែរ ទំលាក់គ្រាប់បែក (យន្ដហោះ B52) លើទីតាំងទ័ពយួននៅចំការអណ្ដូង។ ត្រូវដឹងថា នៅក្នុង សមរភូមិ ចេនឡា ទ័ពអាកាសអាមេរិកាំង ជួយខ្មែរ តែម្ដងនេះទេ។ តែជំនួយនេះ វាខនពេល ១៥ថ្ងៃទៅហើយ ព្រោះ ពលានុភាពអាវុធ (puissance de feu) នៃទ័ពខ្មែរ វាស្ថិននៅក្នុងសភាព ហីន

ភាព ដោយប្រៀបធៀបនឹងពលានុភាពអាវុធយួន។ តែពួកឧត្តមសេនីយ អាមេរិកាំង មានយុទ្ធសាស្ត្រមួយ នៅស្រុកយួន គឺ នៅពេលជួបប្រទះអាវុធ គឺទុកឲពួកកុម្មុយនិស្ត បញ្ចេញគ្រប់មធ្យោបាយសិន ហើយ មានអារម្មណ៍ថាកំពុងឈ្នះ មុននឹង វៃតាមផ្លូវអាកាស (frappe aérienne) ទីតាំងខ្មាំង ដើម្បីកំទិចឲបានច្រើនជាដាច់ខាត ព្រោះថាបើវៃភ្លាម គឺនាំអោយពួកកុម្មុយនិស្ត វាដកខ្លួនចេញភ្លាមពីសមរភូមិ។

ទ័ពយួនខាងជើង វាយផ្តាច់ចុងក្រោយ មកលើទ័ពខ្មែរ នៅស្រុកប្រាកង ស្ថិននៅរវាង ស្រុកស្គួន និង តាំងគោក។ ជាសមរភូមិក្តៅណាស់ ព្រោះទ័ពខ្មែរ វាយទប់ទល់ដ៏ខ្លាំងក្លាវិញ តែទីបញ្ចប់ ត្រូវទទួលបរាជ័យ ព្រោះទីតាំង ប្រាកងត្រូវបានខ្មាំង ចូលកាន់កាប់បាន នៅថ្ងៃទី៣ ធ្នូ។ យួនប្រើកាំភ្លើងធំទំនើបៗ ដូចយ៉ាង កាំភ្លើងធំមធ្យម ឥតធាក់ថយក្រោយ ( canons sans recul de 57 et 75mm) និង កាំភ្លើងបាញ់ រ៉ូកែត (les lance-roquettes RPG-2) ដ៏មានប្រសិទ្ធភាព សំរាប់បាញ់រថក្រោះខ្មែរ។

នៅថ្ងៃទី ១៤ វិច្ឆកា លោក លន់ នល់ និង ឧត្តមសេនីយ ហូ ហង់ស៊ីន ប្រជុំគ្នា ដើម្បីពិនិត្យ ស្ថានភាព លើសមរភូមិ ចេនឡា តែអ្នកទាំងពីរ គ្មានប្តូរផែនការ នៃប្រតិបត្តិការ អ្វីនោះឡើយ។ ហាក់បីដូចជា ប្រធានបទ ចេនឡា គ្មានសារៈសំខាន់ ទៀតទេ ចំពោះ លន់ នល់។ សមរភូមិ ក្តៅ ដែល

លោក លន់ នល់ មានចំណាប់អារម្មណ៍ នៅពេលនោះ គឺ ការពារផ្លូវជាតិ លេខ៤ ឯណោះទៅវិញ។ គេសួរថា តើ ឧត្តមសេនីយ ហូ ហង់ស៊ីន គាត់ លាក់ ការពិត ចំពោះ លោក លន់ នល់ ឬ គាត់ ខ្លួនឯង មិនដឹង ការពិត តែម្តង ?

ចេនឡា ចាប់ពីខែវិច្ឆកាទៅ គឺ វេរចេនៈនឹងន័យថា ‹រកផ្លូវរស់សំរាប់ខ្លួនឯង›។ ឧត្តមសេនីយ ហូ ហង់ស៊ីន គ្មានលទ្ធភាពអ្វីក្រៅពីទុកអោយ មេបញ្ជាការ នៃកងឯកភាពនិមួយៗ រកមធ្យោបាយ រត់ចេញពី សំណាញ់ខ្មាំង ដោយខ្លួនឯង។ តែត្រូវដឹងថា ខ្មាំងដេញតាម យ៉ាងស្អិត គ្រប់ច្រកល្ហក់ ហើយបាញ់សម្លាប់ទាហ៊ានខ្មែរ ឥតត្រាប្រណីយ។ អ្នកដែលរត់រួច គឺ ស្ថិតនៅក្នុង សភាព ហេវហត់ និងធ្លាក់ទឹកចិត្តជាទីបំផុត។ មុននឹងយួន វាយបែក ទីតាំងសឹកខ្មែរនៅស្រុកប្រាកង លោក លន់ នល់ និង ឧត្តមសេនីយមួយចំនួន នៃអគ្គសេនាធិការ នៃកងទ័ពជាតិ បានមកសមរភូមិ ឃើញច្បាស់ នូវទស្សនីយភាព ស្រងូតស្រងាត់ នៃទាហ៊ានខ្មែរ ដែលបានរត់រួចពី ការឡោមព័ទ្ធខ្មាំង តែ ពួកអ្នកចាំតែបង្អាប់លោក លន់ នល់ គេខ្សឹបថា ពួកគេសង្កេតឃើញ ទឹកមុខ លោកនៅស្ងើ មិនចេញវាចាអ្វីឡើយ រហូតលោក ឡើង ឧទ្ធម្ភាចក្រ ត្រឡប់ទៅភ្នំពេញវិញ។ អ្នកសង្កេតការខ្លះ យល់ឃើញថា លោក លន់ នល់ គាត់ហាក់បីដូចជា មិនជឿសោះ នូវបរាជ័យខ្មែរ នៅ

ចំពោះខ្មាំងយួន នោះឡើយ។ តែចំពោះ មតិជាតិមួយចំនួន គេយល់ឃើញថា បរាជ័យជាក់ស្ដែងនេះ វាអាចចោទជាបញ្ហា ដល់ អាយុជីវិត នៃរបបសាធារណរដ្ឋខ្មែរ តែម្ដង ក្នុងអនាគតដ៏ខ្លីមួយ។

## ពេលវេលា នៃ តុល្យការ

បរាជ័យ នៃប្រតិបត្តិការសឹក ចេនឡាទី២ វានាំឲមានការបាត់បង់ នៃចំនួន ១០ កងវរសេនាតូច ដ៏ឆ្នើម និង ១/៣ នៃសម្ភារៈយោធា របស់កងទ័ពជាតិ។ ទាហ៊ានខ្មែរ ស្លាប់ និង បាត់ខ្លួន នៅក្នុង សមរភូមិ មានចំនួន ប្រមាណ ១២.០០០ នាក់[5]។ ប្រជាជន ស្លាប់ជាច្រើនណាស់ដែរ តែគេពុំបានដឹង ចំនួនពិតនោះទេ។ ហេដ្ឋារចនាសម្ព័ន្ធ ដូចយ៉ាង ស្ពាន និង ផ្លូវថ្នល់ តាមផ្លូវជាតិ លេខ៦ ត្រូវបានបាក់បែក និង ខូចខាតយ៉ាងច្រើន។ តែ ចេនឡា បានរំដោះ ប្រជាជនខ្មែរ ដែលរស់នៅក្នុងដំបន់យួនកាន់កាប់រាប់ម៉ឺននាក់។ បរាជ័យនោះ ចោទជាសំនួរថា តើកងទ័ពជាតិខ្មែរ អាចមាន សមត្ថភាព ប្រឈរមុខទល់នឹង កងទ័ពយួនកុម្មុយនិស្ត ដែលគេទុកជា កងទ័ព មានការពិសោធ ក្នុងការធ្វើសង្គ្រាម អស់រយះពេលយូរមកហើយ ? ហើយ តើនរណា ជាអ្នកទទួលខុសត្រូវ នៃបរាជ័យនោះ ?

[5] ចំនួននេះ កងទ័ពខ្មែរ មិនដែលបង្ហាញជាផ្លូវការនោះឡើយ។ វាអាចជាការឃោសនា របស់ខ្មាំងផងដែរ។

## ១. ការផ្តួចផ្តើមគំនិត

ពួកអ្នកសង្កេតការអន្តរជាតិ យល់ឃើញថា ប្រតិបត្តិការចេនឡា ជាកំហុសមួយ របស់លោក លន់ នល់ ព្រោះគាត់ជាអ្នកផ្តួចផ្តើមគំនិត ដើម្បី បំរើប្រយោជន៍នយោបាយច្រើនជាង ប្រយោជន៍យោធា។ អ្នកខ្លះទៀតយល់ឃើញថា លោក លន់ នល់ គាត់ចង់បង្ហាញអាមេរិកាំងថា ទ័ពខ្មែរអាចមាន ដើមគំនិត និង សេចក្តីក្លាហាន វៃលុក យួនកុម្មុយនិស្ត ដើម្បី រំដោះ ទឹកដី និង ប្រជាជនខ្មែរ បាន។ យោបល់ទាំងឡាយនេះ វានាំឲមាន ភាពចម្រូងចម្រាសនៅក្នុងប្រទេស ក៏ដូចនៅក្រៅប្រទេស។ ចំពោះ លោក លន់ នល់, ចេនឡា ជា ការឆ្លើយតបនឹង សេចក្តីស្រើបចិត្ត នៃយុវជនខ្មែរ ដែលប្តេជ្ញាចិត្ត ប្រឆាំងនឹង ការឈ្លានពានយួនកុម្មុយនិស្ត។ ក្នុងចំណុចនេះ គេអាចចាត់ទុកជា ប្រយោជន៍នយោបាយ សំរាប់ ពង្រឹក ការតស៊ូខ្មែរ។ តែ នៅពេលនោះ តើ សមត្ថភាពយោធាខ្មែរ វាមានកំពស់ស្មើនឹង សេចក្តីប្តេជ្ញាចិត្ត នោះដែរឬទេ ?

សព លោក អ៊ិន តាំ ជា នយជន[6] (le politique) ខ្មែរ ម្នាក់ នៅពេលនោះ នៅពេលដែលគាត់ត្រូវតែងតាំង ជាមេ

---

[6] ពាក្យនេះ ខ្ញុំធ្លាប់ឃើញលោក អៀវ កើស លោកយកមកប្រើក្នុងន័យអ្នកនយោបាយ។ តែក្រោយមក ពាក្យ អ្នកនយោបាយ ត្រូវបានខ្មែរយើងយកមកប្រើជាទូទៅ ហើយមិនប្រើជាដាច់ខាត នូវពាក្យ នយជន។ ចំពោះខ្ញុំ យកពាក្យនេះ មកប្រើក្នុងន័យបារាំងថា « le politique » គឺជាអ្នកនយោបាយ កាន់អំណាចរដ្ឋ ឬ មានការទទួលខុសត្រូវ ក្នុងវិស័យណាមួយ ដូចយ៉ាង ជា រដ្ឋមន្ត្រីជាឧទាហរណ៏។

*(note de bas de page - suite)*

បញ្ជាការសឹក ភូមិភាគទី១[7] បានឆ្លើយសំនួរ នៃ អ្នកការសែតបរទេសអំពី គោលចំណង់ចិត្តគាត់ ថា : ‹ការវៃតប នឹង ការឈ្លានពាន ដាក់ស្តែង នៃយួនកុម្មុយនិស្ត វាមិនមែនស្ថិតនៅលើ សេចក្តីក្លាហាន ឬមិនក្លាហាន របស់ខ្មែរម្នាក់ៗនោះឡើយ គឺវា ជា សភាវគតិ របស់ខ្មែរតែម្តង› (sic)។ សំដីនេះ ជាការលាតត្រដាង នូវទឹកចិត្តខ្មែរ នៅពេលនោះ។ យុវជនខ្មែរ ស្ម័គ្រចូលធ្វើទាហ៊ាន រាប់ម៉ឺននាក់ ហើយទៅ សមរភូមិ ដោយគ្មាន ចិត្តរុញរាបន្តិចឡើយ ដែលនាំឲ ពួកអ្នកកាសែតបរទេស ដាក់ឈ្មោះថា ‹ទាហ៊ាន ២៤ ម៉ោង›។ កងឯកភាពនិមួយៗ មានលាយ ទាហ៊ានចាស់ពាក់កណ្តាល ទាហ៊ានថ្មីពាក់កណ្តាល ហើយអ្នកចាស់ធ្វើគ្រូអ្នកថ្មី នៅលើសមរភូមិ។ យោគតាមសំដី លោក អ៊ុន តាំ, ខ្មែរ ទាំង ជនស៊ីវិល និង ទាហ៊ាន អាចទុក ចេនឡាជា សេចក្តីថ្លើងចិត្ត របស់ខ្លួន ចំពោះមុខខ្មាំងសួរពូជ។ គោលជំហរ អាមេរិកាំង នៅពេលនោះ វានៅមិនទាន់ច្បាស់លាស់នៅឡើយថា ត្រូវជួយខ្មែរ ដល់កំរិតណាមួយ។ ប្រតិបត្តិការសឹករួម អាមេរិកាំង និង យួនខាងត្បូង ចូលក្នុងទឹកដីខ្មែរ ចម្ងាយ ៣០ គ.ម. និង កំរិតពេលវេលា ២ ខែ គ្មានគោលដៅជួយខ្មែរនោះទេ គឺគេធ្វើឡើង សំរាប់ប្រយោជន៍គេសុទ្ធសាធ ព្រោះគេ ឥតបានប្រាប់ខ្មែរ ជា

[7] លោក អ៊ុន តាំ ជា នាយទាហ៊ានបម្រុងជំនាន់ទី៤។ ពេលស្រុកខ្មែរ កើតសង្គ្រាម នៅឆ្នាំ ១៩៧០ លោក ចូលបំរើក្នុងក្រុបខណ្ឌយោធា ក្នុង ឋានន្តរសក្តិ ជា ឧត្តមសេនីយត្រី។ លោក ក៏ជា អតីតសិស្ស សាលារដ្ឋបាលខ្មែរដែរ។

មុននោះឡើយ។ ប្រតិបត្តិការសឹកនោះ នាំឲពួកយួន កុម្មុយនិស្ត រុលចូលមកក្នុងទឹកដីខ្មែរ កាន់តែជ្រៅឡើង ដើម្បីគេច ការវាយប្រហារ អាមេរិកាំង-យួនខាងត្បូង។ ពេលនោះ លោក អ៊ិន តាំ គាត់បញ្ចេញយោបល់ផ្ទាល់ខ្លួន ថា : អាមេរិកាំង មិនស្គាល់ខ្មែរច្បាស់ទេ ដែលនាំ យួនខាងត្បូង ចូលមកក្នុងស្រុកខ្មែរ ព្រោះនាំអោយខ្មែរ លែងយល់ ត្បិត ឃើញទាហ៊ានខ្មែរ កំពុងច្បាំងដេញ យួនខាងជើង ចេញពីស្រុក តែបែរជាឃើញ យួនខាងត្បូង ដើរចូលមកក្នុងស្រុកវិញ[8]។ ព្រោះវិស័យមតិខ្មែរជាទូទៅ គឺ យួន មានចិត្តតែមួយ គឺ គំរាមជានិច្ច។ សំដីនេះ ដែលនាំ ឲ មន្ត្រីទូតអាមេរិកាំងខ្លះ មានមតិ ចំពោះលោក អ៊ិន តាំ ថា លោក ជា នយជន វាងវៃណាស់ ក្នុងវិស័យនយោបាយ និង ជា សុចរិតជនខ្មែរមួយរូប តែលោក ខ្វះ នូវការយល់ដឹងអំពីការពិត នៃនយោបាយទូត។ សួរថា តើមតិលោក អ៊ិន តាំ អាចចាត់ទុកបានថាជា ការខុសឆ្គង របស់សហរដ្ឋអាមេរិកនៅស្រុកខ្មែរ ?

8 ទ័ព យួនខាងត្បូង ចំនួន ១២. ០០០ នាក់ ដឹកនាំ ដោយ ឧត្តមសេនីយ យួន ឈ្មោះ Do Cao Try ចូលមកក្នុងដំបន់ចំពុះទា ក្នុងខេត្ត ស្វាយរៀង។

*(note de bas de page - suite)*

នៅក្នុង កំណត់ការចងចាំ[9] របស់ឧត្តមសេនីយឯក សុស្តែន ហ្វែរណង់ដេស[10], អតីត អគ្គមេបញ្ជាការ និង អគ្គនាយសេនាធិការ នៃកងយោធពលខេមរភូមិន្ទ (១៩៧២-១៩៧៥), លោក បានរៀបរាប់ អំពីប្រតិបត្តិការ ចេនឡា ទី១-ទី២ មានដូចខាងក្រោមនេះ (បកប្រែក្រៅផ្លូវការ) :

ឧត្តមសេនីយ លន់ នល់ នៅក្នុងអំឡុងខែ តុលា ឆ្នាំ ១៩៧០ លោក បានរៀបចំ ប្រតិបត្តិការសឹក វាយលុកធំមួយ ប្រឆាំងនឹង កងទ័ព ពួកកុម្មុយនិស្ត ដែលលោក ឲឈ្មោះ ដោយ គ្មានលំឱនចិត្តសោះឡើយ គឺ ‹ជ័យជំនះទាំងស្រុង›។ ប្រតិបត្តិការសឹកនោះ មានឈ្មោះថា ចេនឡា ទី១ ចាប់ផ្តើម ពីដើមខែកញ្ញា ឆ្នាំ ១៩៧០។ នៅខែ កញ្ញា ឆ្នាំ ១៩៧១ មានប្រតិបត្តិការសឹកមួយទៀត ឈ្មោះ ចេនឡាទី២។ ប្រតិបត្តិការសឹកទាំងពីរនោះ គឺ ឧត្តមសេនីយ លន់ នល់ លោក ជាអ្នករៀបចំផ្ទាល់ ដោយមានជំនួយពីឧត្តមសេនីយ សាក់ សុតសាខន។ ចេនឡា ទទួលនូវបរាជ័យ ទាំងស្រុង និង ឮខ្ទរខ្ទារ ពេញស្រុកខ្មែរ នៅខែវិច្ឆការ ឆ្នាំ ១៩៧១។ គោលការចម្បង នៃ ចេនឡាទី១ និង

---

[9] Mémoires d’une guerre oubliée par le Lieutenant Général Sosthène Fernandez, ancien Commandant en Chef et Chef d’Etat-Major Général de l’Armée nationale khmère - Edition AsieInfo.

[10] ឧត្តមសេនីយឯក ស. ហ្វែរណង់ដេស លាលែងពីដំណែងនៅ ថ្ងៃទី ១២ មីនា ឆ្នាំ ១៩៧៥ ដោយមានការបង់ខំ ពី លោក លន់ នល់ ព្រោះមានទំនាស់លើឋាន យុទ្ធសាស្ត្រ នយោបាយ-យោធា ស្តីពី ការចរចាជាមួយពួកខ្មែរក្រហម។ ឧត្តមសេនីយឯក សាក់ សុតសាខន ត្រូវបានតែងតាំងក្នុងតំណែងជំនួសលោក។

ទី២ គឺ រំដោះ តំបន់ ពាយ័ព្យ នៃរដ្ឋធានី និង បើកផ្លូវជាតិ ពីស្រុកស្គន់ ទៅ ទីក្រុងកំពង់ធំ ដែលជា ក្រុងកសិកម្មធំមួយ របស់ស្រុកខ្មែរ ហើយជា ដំណាក់ការ ទៅកាន់ទីក្រុងសៀមរាប (អង្គរ)។ ខ្មាំងបានកាន់កាប់ផ្លូវនោះ មានតាំងទីទ័ព នៅភ្នំសន្ទុក និង នៅចំការកៅស៊ូ អណ្តូង។ ប្រតិបត្តិការសឹកចេនឡា គឺ រំដោះតំបន់ផង និង រក្សាមិនឲដាច់ នូវការផ្គត់ផ្គង់ពស្តុភារ ឬ ការផ្តល់ស្បៀង ពីភ្នំពេញ ទៅ កំពង់ធំផង។

ឧត្តមសេនីយ លន់ នល់ ប្រគល់បេសកកម្មនោះ ដល់ កងពលតូច ដ៏ឆ្នើម ពីរកង គឺ កងលេខ១ និង លេខ២, គាំទ្រដោយ របក្រោះ និង កាំភ្លើងធំ។ ចំនួនយោធាទាំងអស់មាន ៥.០០០ នាក់ ដើរតៗគ្នា តាមផ្លូវជាតិលេ៦ ដែលនៅក្បែរផ្លូវ មានភ្នំតូចធំឡាំងឡាយ ដែលវាមិនប្រសើរសោះយោងតាមកលល្បិចសឹក។ កំហុសដ៏ធំ របស់ចេនឡាទី២ គឺ វាមាននៅក្នុងក្បួនសឹករួចស្រេច សំរាប់ខ្មាំង គឺ ទុកឲទ័ពខ្មែរ ដើរចូលជ្រៅ ក្នុងដំបន់ការពាររបស់ខ្លួន ហើយវាយ កាត់ផ្តាច់ទ័ពខ្មែរជាកំណាត់ៗ រួចហើយ វាយយ៉ាងខ្លាំងក្លា ទៅលើ កំណាត់និមួយៗ ដោយមិនឲទ័ពខ្មែរ អាចមានលទ្ធភាព រៀបចំ នូវការវៃតបវិញបាន ជាដាច់ខាត។ ការវាយបែបនេះ គឺ មិនគ្រាន់តែអាច សម្លាប់រពាយ ទាហ៊ានខ្មែរ គឺវាជា សេចក្តីវិនាសដ៏ធំ នៃ សម្ភារះយោធាថែមទៀត។ គេដឹងថា ខ្មាំងបានប្រមូល យកពីទ័ពខ្មែរ

បាន នូវគ្រាប់រំសេវ ដែលអាចប្រើ សំរាប់ច្បាំង យ៉ាងតិចណាស់ ចំនួន៣ខែ។ គ្រប់ឋានទាំងអស់ គឺមាន តុល្យការអវិជ្ជមាន និង គួរឲភ័យខ្លាច។ លទ្ធវត្ថុ ទាំងឡាយ (choses acquises) ដែលកងទ័ពជាតិខ្មែរ ខំប្រឹងយកវាបានលើសមរភូមិ តាំងពីទម្លាក់ សម្តេច សីហនុ មក ត្រូវខ្មែរ សើរើវា វិញបាន។ តែ ចេនឡា ក៏បង្ហាញថា នៅលើសមរភូមិ គឺមានសុទ្ធតែ ទាហ៊ានយួនកុម្មុយនិស្ត ដែលវាផ្ទុយពី ការឃោសនា របស់សម្តេច សីហនុ ថា ទ័ពខ្មែរ រំដោះ ជាអ្នកវាយ កងទ័ពសាធារណរដ្ឋខ្មែរ នៅពេលនោះ។

## ២. ការទទួលខុសត្រូវ

បរាជ័យ ចេនឡាទី២ ត្រូវពួកអ្នកនយោបាយ លើកចោទជាសំនួរថា តើនរណាជាអ្នកទទួលខុសត្រូវ ? លោក លន់ នល់, សាក់ សុតសាខន ឬ ពួកមេបញ្ជាការទ័ព នៅលើសមរភូមិ ?

នៅក្នុង កំណត់ការចងចាំ[11] របស់ ឧត្តមសេនីយឯក សាក់ សុតសាខន លោក មិនបាន លើកមកនិយាយ អំពីចំណុចណាមួយ ដែលទុកជាកំហុស កលល្បិច និង យុទ្ធសាស្ត្រ ដូចលោក សុស្តែន ហ្វែរណង់ដេស នោះទេ។ លោក គ្រាន់តែរៀបរាប់អំពី ដំណើរ នៃប្រតិបត្តិការ នៅលើសមរ

[11] The khmer Republic at War and the Final Collapse - U.S. ARMY OF MILITARY HISTORY.

ភូមិ តែប៉ុណ្ណោះ។ តែ ចំពោះអ្នកនយោបាយខ្មែរទូទៅ គេយល់ឃើញថា អ្នកទទួលខុសត្រូវ គឺ លោក លន់ នល់ ព្រោះលោក នៅពេលនោះជា អ្នករៀបចំ ផែនការសឹក ក្នុងឋានៈលោកជា អគ្គនាយសេនាធិការ នៃកងយោធពលខេមរជាតិ។ តែគ្មាននរណាមួយ អាចបន្ទោសលោកបានឡើយ ព្រោះនៅពេលនោះ លោក ជា មេដឹកនាំខ្លាំងម្នាក់ នៃរបបថ្មី។ តែ ទ្រង់ សិរិមតៈ, លោក ចេង ហេង និង អ៊ិន តាំ ដែល ចែករំលែកគំនិតនោះ ក៏នាំគ្នា សម្រេចចិត្ត លើកបញ្ហានោះ មកដោះស្រាយ ដោយ ស្នើសុំឲ លោក Emory Swank ភារធារី អាមេរិកាំង នៅស្រុកខ្មែរជំនាន់នោះ អោយស្នើសុំដល់លោក លន់ នល់ ឲតែងតាំង អ្នកទទួលខុសត្រូវច្បាស់លាស់ ក្នុងវិស័យ យុទ្ធសាស្ត្រ និង កលល្បិចយោធា ក្នុងឋានៈជា អគ្គមេបញ្ជាការ និង អគ្គនាយសេនាធិការ នៃកងយោធពលខេមរជាតិ ក្រៅពីរូប លោក លន់ នល់ ដែល ជា នាយករដ្ឋមន្ត្រី។ ក្រោយពីបានគិតពិចារណាយូរបន្តិចមក លោក លន់ នល់ សុទ្ធចិត្តធ្វើតាមសំណើរនោះ។ តែ លោក ស្នើឈ្មោះ ឧត្តមសេនីយ ឋាភានាងិន តែពេលជាមួយគ្នានោះដែរ លោក ភារធារី ក៏បានស្នើឲទ្រង់ សិរិមតៈ ស្នើឈ្មោះឧត្តមសេនីយ ម្នាក់ទៀតដែរ ដើម្បី យកមក ទូរគ្នា។ ទ្រង់ បានស្នើ ឈ្មោះ ឧត្តមសេនីយ សុស្តែន ហ្វែរណង់ដេស។ លោក Emory Swank ក៏យកឈ្មោះទាំងពីរនោះ ទៅជម្រាបលោក លន់ នល់ ហើយស្នើ

ដល់លោកថា គួរធ្វើការសិក្សា ទៅលើ គុណសម្បត្តិ និង គុណវិបត្តិ ឲបានម៉ត់ចត់ តាមបែបជ្រើសរើសទំនើប មុននឹងតែងតាំង អ្នកណាមួយ។ ក្រោយពីបាន ពិច័យ មក អាមេរិកាំង បានស្នើឈ្មោះលោក ស. ហ្វៃរណង់ដេស ដែលគេទុកថាលោក មាន គុណសម្បត្តិ ជា អ្នកយុទ្ធសាស្ត្រ ជា អ្នកបច្ចេកទេស យោធា និង ជា អ្នក មានសមត្ថភាព ដឹកនាំនូវផនផានមនុស្ស ទំច្រើនជាង ឧត្តមសេនីយ ឋា ភានា ដិន។

## ៣. សមត្ថភាព

បរាជ័យ ចេនឡាទី២ ក៏មានចោទជាសំនួរថា តើលោក លន់ នល់ លោក មានសមត្ថភាពយោធា គ្រប់គ្រាន់ សំរាប់ ដឹកនាំសង្គ្រាម ដែរឬទេ ? តើ កងទ័ពខ្មែរ អាចនឹង ប្រកួតប្រជាំងនឹង កងទ័ពយួនកុម្មុនិស្ត បានដែរឬទេ ? តើ របបសាធារណរដ្ឋខ្មែរ អាចមានលទ្ធភាព ប្រមូល កម្លាំងជាតិខ្មែរ សំរាប់តស៊ូ ប្រឆាំងនឹង កម្លាំងកុម្មុយ និស្ត បានដែរឬទេ ?

**អំពី សមត្ថភាពយោធា របស់លោក លន់ នល់** : មុននឹង និយាយអំពី សមត្ថភាពយោធា គួររំឭកថា នៅខែកុម្ភ: ឆ្នាំ ១៩៧១ លោកមានជម្ងឺ ខ្វិនជើង ដោយសារ រលាកខួរ ក្បាល។ បន្ទាប់ពីបាន ព្យាបាលជម្ងឺរួចមក កាយរបស់

លោក បាត់បង់ នូវចលនភាព ជាង ៥០%។ គេអាចស្មាន បានដែរថា ប្រាជ្ញារបស់លោក ក៏អន់ថយខ្លាំងណាស់ដែរ។ ដូច្នេះ ជម្ងឺរបស់លោកនេះ វាអាចនឹងដូរ អត្តរបស់លោក តែម្តង ដែលនាំ អ្នកនយោបាយខ្មែរ ទាំងឡាយ មាន មន្ទិលទៅលើ សមត្ថភាពសតិបញ្ញា របស់លោក ក្នុងការ ដឹកនាំជាតិ និង សង្គ្រាម។

លោក លន់ នល់ លោក មិនមែនជា យោធាអាជីព នោះ ទេ។ មុខវិជ្ជា របស់លោកពីដើម គឺជា ចៅក្រម តែនៅ ពេលដែលសម្តេច សីហនុ ទ្រង់ ធ្វើបូជនីយកិច្ច ទាមទារ ឯករាជ្យ ពីបារាំង លោក បានស្ម័គ្រចិត្ត ចូលធ្វើទាហ៊ាន ក្នុងឋានន្តរស័ក្តិ ជា វរសេនីយត្រី ប្រដូច។ ក្រោយពីខ្មែរ ទទួលបានឯករាជ្យជាតិបរិបូរណ៍មក កងទ័ពជាតិ បាន អនុញ្ញាតឲពួកនាយទាហ៊ានប្រដូច អាចចូល ក្របខណ្ឌ យោធាបាន។ នៅពេលនោះ លោក លន់ នល់ លោក ក៏ សម្រេចចិត្តចូលក្របខណ្ឌយោធាទៅ។ តែ លោក មិន បានចូល ធ្វើការសិក្សាអាជីព នៃមុខវិជ្ជាយោធាម្តងណា ឡើយ។ លោក គ្រាន់តែរៀននៅកន្លែងធ្វើការ តាមគ្រប់ មុខងារ ដែលលោក ត្រូវបានតែងតាំង ជាមួយនឹងនាយ ទាហ៊ានអាជីព ដែលនៅក្រោមបង្គាប់លោក ជាពិសេស ជាមួយ លោក ស. ហ្វែរណង់ដេស ដែលលោកតែងតែយក មកធ្វើការជាមួយលោក តាំងពីលោក ជា មេតំបន់ ខេត្ត បាត់ដំបង រហូតមកដល់លោក មកកាន់មុខដំណែងជា

អគ្គនាយសេនាធិការ នៃកងយោធពលខេមរភូមិន្ទ, នៅពេលនោះលោកបាន តែងតាំង លោក ស. ហ្វែរណង់ដេស ជា អគ្គនាយសេនាធិការរង។ តែចំណុចនេះ តើគេអាចចាត់ទុកថាជា ចំណុចខ្សោយរបស់លោក លន់ នល់ បានដែរឬទេ ? បាន ក៏ថាបាន, ទេ ក៏ថាបាន ព្រោះថា មានអ្នកដែលមិនមែនជា យោធាអាជីព តែគេ អាចមានសមត្ថភាព ដឹកនាំសង្គ្រាមបាន ដូចយ៉ាង ឧត្តមសេនីយ យួនកុម្មុយនិស្ត ឈ្មោះ វូ ង្វៀង យ៉ាប់។ តួនាទី របស់លោក លន់ នល់ មិនស្ថិតនៅក្នុង វិស័យយោធា បរិសុទ្ធនោះឡើយ, តួនាទី របស់លោក គឺជា នយជន ដឹកនាំ នូវបដិវត្តន៍ របស់ប្រជាជាតិខ្មែរតែម្តង។ ក្នុងចំណុចនេះឯងដែលអាចចោទជាសំនួរថា តើលោក លន់ នល់ គាត់មានកំពស់ សតិបញ្ញា និង គោលចំណង់គ្រប់គ្រាន់ ដែរឬទេនៅចំពោះមុខ បញ្ហាប្រឈមមុខ (défi) នេះទេ ?

## អំពី សមត្ថភាព នៃកងទ័ពជាតិខ្មែរ

ខ្មែរ តែងទុកខ្លួនជាពូជអ្នកចម្បាំង។ គំនិតនេះ វាជាការចាំបាច់ នៅពេលស្រុកមានសង្គ្រាម តែវាមិនគ្រប់គ្រាន់នោះឡើយ ព្រោះសង្គ្រាម ជាកិច្ចការអាជីព ដូចយ៉ាង ត្រូវមាន ការអប់រំចិត្ត, ហ្វឹកហ្វឺន នូវកម្លាំងកាយ, ហ្វឹកហ្វឺន នូវបច្ចេកទេសយោធា ទៅតាមថ្នាក់ នៃតួនាទី, សិក្សា នូវកលល្បិច និង យុទ្ធសាស្ត្រសឹក ទៅតាមថ្នាក់ នៃការទទួល

ខុសត្រូវ ។ល។ កងទ័ពជាតិខ្មែរ គឺបារាំង ជាអ្នកជួយបង្កើត នៅខែ វិច្ឆកា ឆ្នាំ ១៩៤៥ មានឈ្មោះថា កងយោពលខេមរភូមិន្ទខ្មែរ ហើយជួយ ក្នុងវិស័យ ហ្វឹកហ្វឺន នាយទាហ៊ានរង រហូតដល់ថ្នាក់ នាយជាទាហ៊ានជាន់ខ្ពស់ និង ផ្តល់ជាជំនួយ សម្ភារៈយោធា គ្រប់បែបយ៉ាង។ តែបន្ទាប់មក បារាំង ជាប់ដៃច្បាំងខ្លាំងនឹងយួនកុម្មុយនិស្ត នៅស្រុកយួន ក៏គេមិនសូវមានពេលវេលាផង និង មានសម្ភារៈផង ជួយខ្មែរ។ ក្រោយពី សន្និសិទ្ធ នៅទីក្រុង ស្សឺណែវ កងទ័ពខ្មែរ បានទទួលជំនួយ ជាសម្ភារៈយោធា ពីសហរដ្ឋអាមេរិក តែឋានៈជំនួយនោះ វាមិនគ្រប់គ្រាន់នោះឡើយ សំរាប់ រៀបចំកងទ័ព អោយមានភាពទំនើប ដូចកងទ័ពសៀម និង យួន។ មកដល់ឆ្នាំ ១៩៦៣ សម្តេច សីហនុ ទ្រង់ប្រកាសឈប់ ទទួលជំនួយអាមេរិកាំង ទាំងវិស័យ សេដ្ឋកិច្ច និង យោធា។ តែទ្រង់ មានបន្ទូលថា ទ្រង់ ទទួលជំនួយយោធា សាធារណរដ្ឋចិនប្រជាមានិត ជំនួស ជំនួយអាមេរិកាំង ព្រោះចិន គេធានាថានឹង ធ្វើឲកងទ័ពខ្មែរក្លាយជា កងទ័ពទំនើប និង ស័ក្តសិទ្ធ។ នៅសម័យ សង្គមរាស្ត្រនិយម សម្តេច សីហនុ ទ្រង់ យកកងទ័ពជាតិ មកប្រើនៅក្នុង វិស័យសេដ្ឋកិច្ច ដែលនាំឲ ឋានៈអាជីព នៃកងទ័ព ធ្លាក់កំរិតយ៉ាងងខ្លាំង ព្រោះគ្មានពេលវេលា គ្រប់គ្រាន់ សំរាប់ហ្វឹកហ្វឺន នៃការបន្តការសិក្សាផង និង កង្វះថវិកា សំរាប់ធ្វើអភិវឌ្ឍផង។ វាហាក់ជា សម្តេច សីហនុ

ទ្រង់ គ្មានការយកចិត្តទុកដាក់ ដល់កងទ័ពជាតិ សំរាប់ការពារជាតិ សោះឡើយ ដែលនៅពេលនោះ ស្រុកខ្មែរ រស់នៅក្បែរ ភ្លើងសង្គ្រាម ខ្លាំងក្លាមួយ។ ប្រហែលជាទ្រង់ យល់ឃើញថា នយោបាយ នៃអព្យាក្រិតភាព ផ្អៀងទៅ ឆ្វេង ដោយយក ចិនប្រជាមានិត ជាបង្អែករបស់ទ្រង់ វាជាខែលមាំមួន សំរាប់ការពារប្រជាជាតិបាន នៅចំពោះមុខ យួនកុម្មុយនិស្ត។
ដូចបានជំរាបខាងលើរួចមកហើយថា នៅថ្ងៃទី២៧ មីនា ឆ្នាំ ១៩៧០ កងទ័ពយួនកុម្មុយនិស្ត បានវាយកងទ័ពខ្មែរ, នៅពេលនោះកងទ័ពខ្មែរ មានធនធានមនុស្ស និង សម្ភារៈយោធា តិចតួចណាស់ សំរាប់វាយតបខ្លាំងវិញ។ ពួកមេទ័ពយៀកកុង មានជំនឿជាក់ច្បាស់ថា គេនឹងវាយឈ្នះកងទ័ពខ្មែរ តែមួយសប្តាហប៉ុណ្ណោះ។ ពីថ្ងៃទី ២៧ ដល់ថ្ងៃទី ១៤ មេសា កងទ័ពខ្មែរ ទប់ទល់យៀកកុង នៅគ្រប់សមរភូមិ មានឈ្នះ មានចាញ់ តែមិនរលំនោះឡើយ តែកងទ័ពខ្មែរ ចាប់ផ្តើម ខ្វះគ្រាប់រំសេវ និង សម្ភារៈយោធា គ្រប់គ្រាន់ សំរាប់បន្តទប់ទល់។ ដូច្នេះ នៅថ្ងៃទី ១៤ មេសា លោក លន់ នល់ បានសម្រេចចិត្ត សុំជំនួយ អាមេរិកាំង តែគ្មានចម្លើយសោះ រហូតដល់ថ្ងៃទី ២២ មេសា ជាថ្ងៃដែលខ្មែរ ស្នើសុំជាថ្មី។ ទើបមកដល់ថ្ងៃទី២៧ មេសា ទើប អាមេរិកាំង សម្រេចផ្តល់ ជំនួយដល់កងទ័ពខ្មែរ ហើយដឹកជញ្ជូន សម្ភារៈយោធាចាប់បាច់ មកដល់ស្រុកខ្មែរ។ ពី ថ្ងៃទី ១៤

មេសា មកដល់ ថ្ងៃទី ២៧ មេសា ជារយៈពេលមួយ ដែលកងទ័ពខ្មែរ ធ្វើចម្បាំងនឹងទឹកចិត្តសុទ្ធសាធ ព្រោះខ្វះសម្ភារៈ គ្រប់យ៉ាង នៅចំពោះកងទ័ពយៀកកុង ប្រដាប់អាវុធទំនើប និង មានការពិសោធ។ លោក Nicolas Lang អ្នកនិពន្ធបារាំងសែសម្នាក់ បានសរសេរថា : *យុវជនខ្មែរ វុលចូលវាយខ្លាំង ប្រកបដោយ សេចក្តីក្លាហាន និង សប្បាយរីករាយ ជាក់ស្តែង។*

ចំណាប់អារម្មណ៏នេះឯង វាជាទឹកចិត្ត នៃកងទ័ពខ្មែរ នៅពេលនោះ។ តែ សេចក្តីក្លាហាន នោះ វាមិនគ្រប់គ្រាន់ឡើយ នៅលើសមរភូមិ។ ដូចយ៉ាង នៅលើ សមរភូមិ ចេនឡាទី២ ទាំង លោក លន់ នល់, មេបញ្ជាការកងឯកភាពនិមួយៗ និង ទាហ៊ានខ្មែរ ទាំងឡាយ ខ្វះ នូវការពិសោធ និង សមត្ថភាពបច្ចេកទេសសឹក គ្រប់គ្រាន់ ដែលនាំឲ្យធ្លាក់ទៅក្នុង កលល្បិចខ្មាំង ដែលជាកលល្បិចងាយស្រួលបំផុតសំរាប់វាយយកឈ្នះសត្រូវ។

ឧត្តមសេនីយ យួនខាងត្បូង Do Cao Try  និយាយប្រាប់ក្នីគ្នា (collègue) អាមេរីកាំង គាត់ថា កងទ័ពខ្មែរ មិនអាចស៊ូនឹង ការវាយប្រហារ របស់ពួកយៀកកុង បានជាដាច់ខាត។ សំដីនេះ វាផ្ទុយពីការពិត លើសមរភូមិទាំងឡាយ គឺការវៃតបខ្មែរ មានចាញ់ពិត តែក៏មានឈ្នះនោះដែរ ដូចយ៉ាងនៅសមរភូមិ ស្រុកស្អាង, ទីក្រុងកំពត, ភ្នំបាសិត, ក្រុងកំពង់ចាម, ការការពារក្រុងភ្នំពេញ ។ល។

ដែលអាចឲ កងទ័ពខ្មែរ ប្រឈរមុខទល់នឹង ទ័ពកុម្មុយនិស្តយួន រហូតដល់ទៅ ៥ ឆ្នាំ, រីឯ ទ័ពខ្មែរក្រហម វិញ ដែលអួតក្អេងក្អាងថាខ្លាំងពូកែ តែទប់ជាមួយយួន បានតែមួយសប្ដាហ៍ ប៉ុណ្ណោះ។ ត្រូវដឹងថា ទ័ពជាតិខ្មែរ ដាក់អាវុធដោយសារមេបញ្ជាការ ប្រាប់ឲដាក់អវុធ ប្រគល់ឲពួកខ្មែរក្រហម នៅក្នុង គំនិត បង្រួបបង្រួមជាតិ និង សន្តិភាព តែ គណបក្សកុម្មុយនិស្តខ្មែរ យកជ័យជំនះនេះ សំរាប់សម្លាប់បណ្ដាជនខ្មែរ ដែលនាំឲ ប្រជាជាតិខ្មែរ បាត់នូវកម្លាំងជាតិ សំរាប់ទប់ទល់នឹងការវាយប្រហារ កងទ័ពយួន នៅឆ្នាំ ១៩៧៨។ បើខ្មែរខ្លះ យល់ឃើញថា របបសាធារណរដ្ឋខ្មែរ ជាអ្នកចាញ់ ពួកខ្មែរក្រហម គឺគួរយល់ឃើញដែរថា បណ្ដាជនខ្មែរមួយនគរ ជាអ្នករងគ្រោះនឹងនយោបាយយួនកុម្មុយនិស្ត នៅក្រោមការដឹកនាំ របស់របបកម្ពុជាប្រជាធិបតេយ្យ។ រយះពេល បី ឆ្នាំ ក្នុងសន្តិភាពខ្មែរក្រហម ធ្វើឲប្រជាជនខ្មែរ ស្លាប់ ច្រើនជាង រយះពេលប្រាំឆ្នាំ ក្នុងសង្គ្រាមតស៊ូ របស់ សាធារណរដ្ឋខ្មែរ ប្រឆាំងនឹង យួនឈ្លានពាន ទៅទៀត។

## សេចក្ដីសន្និដ្ឋាន

ចេនឡាទី២ ជាបរាជ័យ ជាក់ស្តែង នៃសមរកម្មមួយ តែ មិនមែនជា ការចាញ់សង្គ្រាម របស់កងទ័ពជាតិខ្មែរ ប្រឆាំងនឹងយួនកុម្មុយនិស្ត នោះទេ។ តែ ចេនឡាទី២

បានបង្ហាញ នូវដែនកំណត់ នៃសមត្ថភាព នៃរបប សាធារណរដ្ឋខ្មែរ ជាអ្នកដឹកនាំ នៃសង្គ្រាមតស៊ូផង និង បដិវត្តន៍ ដើម្បី ប្តូរ របបនយោបាយផ្តាច់ការ និង សង្គម សក្តិភូមិផង។ ដើម្បី មានជោគជ័យ ក្នុងបេសកកម្មនេះ អ្នកដឹកនាំ ត្រូវមានជំនឿ ថាតើងកងទ័ពខ្មែរ ច្បាំង ដើម្បីអ្វី ? ច្បាំងប្រយោជន៍អ្វី ? ទាល់តែអ្នកតស៊ូ មាន ជំនឿសិន ទើបអ្នកទាំងនោះ លើកកាំភ្លើង បាញ់សត្រូវ មានប្រសិទ្ធិភាព, ទើបកងទ័ពជាតិ ក្លាយជាកងទ័ព បដិវត្ត មិនមែន កងទ័ពសំរាប់ស៊ីឈ្នួលច្បាំងទេ។ ក្នុង ន័យនេះហើយ ដែលសង្គ្រាម ប្រើកម្លាំងអាវុធ ត្រូវពឹង ពាក់យ៉ាងជិតស្និទ ទៅលើនយោបាយ ព្រោះថា សង្គ្រាម ប្រើកម្លាំងអាវុធ មានគោលបំណងនឹង វាយដណ្តើមយក មកវិញ នូវទឹកដីដែលខ្មាំង វាយយកទៅកាន់កាប់ទៅ ហើយ ហើយបំផ្លាញឲស្ងូនឡ នូវកម្លាំងប្រយុទ្ធរបស់សត្រូវ រី ឯ នយោបាយ វិញ ត្រូវធ្វើសង្គ្រាមនយោបាយ មានគោល បំណងនឹង ទាក់ទាញទឹកចិត្តប្រជាពលរដ្ឋ ឲមានការគាំ ទ្រពីសំណាក់ប្រជាពលរដ្ឋ ហើយនឹងធ្វើសត្រូវ ឲក្លាយជាស ត្រូវ របស់ ប្រជាពលរដ្ឋតែម្តង និង ឲប្រជាពលរដ្ឋ ចូលរួម ទាំងស្រុង នៅក្នុងដំណើរ នៃបដិវត្តន៍ ប្តូររបបនយោបាយ និង ធ្វើកំណែទំរង់សង្គមជាតិ។

របបសាធារណរដ្ឋខ្មែរ នៅពេលនោះ ច្បាំង ប្រឆាំងនឹង សត្រូវ យួនកុម្មុយនិស្ត ជាអ្នកឈ្លានពានទឹកដីខ្មែរផង

និង ប្រឆាំងនឹង លទ្ធិកុម្មុយនិស្តផង។ នៅពេលនោះ សង្គ្រាម នៅស្រុកយួន ពួកយួនខាងជើង កំពុងតែឈ្នះសង្គ្រាម នយោបាយ ព្រោះ សហរដ្ឋអាមេរិក កំពុងចរចាដកខ្លួនថយពីយៀកណាម តែមិនទាន់ឈ្នះ សង្គ្រាមយោធា នៅឡើយ ព្រោះគេមិនទាន់ វាយយកយួនខាងត្បូងបាន។ តាមការពិសោធ របស់កងទ័ពចិន តៃវ៉ាន់ នៅពេលធ្វើសង្គ្រាម ជាមួយកងទ័ពកុម្មុនិស្តចិន គេពន្យល់ទុកជាមេរៀន ដល់អ្នកធ្វើសង្គ្រាមប្រឆាំងនឹងពួកកុម្មុយនិស្តថា : ក្នុងសង្គ្រាម ពួកកុម្មុយនិស្ត ប្រើដៃ ឆ្វេងផង និង ដៃស្តាំងផង សំរាប់វ៉ៃខ្មាំង។ ដៃឆ្វេង គឺសង្គ្រាមនយោបាយ រីឯដៃស្តាំង វិញ គឺសង្គ្រាមកម្លាំងអាវុធ។ កងទ័ពចិនតៃវ៉ាន់ចាញ់សង្គ្រាមកងទ័ពចិនកុម្មុយនិស្ត ព្រោះខ្លួន មិនសូវយកចិត្តទុកដាក់នឹង សង្គ្រាមនយោបាយ ដោយសារ អាងថាខ្លួន មានកម្លាំងអាវុធច្រើន លើពួកកុម្មុយនិស្ត ដែលទុកឲពួកកុម្មុយនិស្ត តែម្នាក់ឯង ធ្វើសង្គ្រាមនយោបាយ ទាក់ទាញចិត្តប្រជាពលរដ្ឋ និង មតិអន្តរជាតិ ឲគាំទ្រការតស៊ូ របស់គេ។ ជាឧទាហរណ៍ នៅស្រុកយួន នៅពេលណា អាមេរិកាំង វាយប្រហារខ្លាំង តាមគ្រប់មធ្យោបាយ យួនកុម្មុយនិស្ត តែងតែស្នើ ជាបន្ទាន់ឲមាន សន្និសិទ្ធ រកដំណោះស្រាយបញ្ហា តាម សន្តិវិធី។ ការស្នើនេះ វាគ្រាន់តែជាលកល្បិច ដើម្បីរកចំណេញពេលវាលា

និង ដើម្បី បង្ហាញដល់មតិអន្តរជាតិថា ខ្លួនជាអ្នកសន្តិភាពនិយម តែប៉ុណ្ណោះ។

នៅស្រុកខ្មែរ ក្រោយពី បរាជ័យ ចេនឡាទី២ ពួក កុម្មុយនិស្ត ធ្វើការឃោសនា គ្រប់បែបយ៉ាង ដើម្បីបង្ខូចដល់កិត្យានុភាព នូវកងទ័ពជាតិខ្មែរ ថាជា កងទ័ពគ្មានសមត្ថភាព និង កំសាកបំផុត នៅលើសមរភូមិ។ គោលបំណង របស់ពួកកុម្មុយនិស្ត វាមានជ័យជំនះ គឺថា ក្រោយពីចេនឡាទី២ មក មានកើតជម្លោះ រវាង ពួកអ្នកដឹកនាំកងទ័ព នឹង ពួកអ្នកនយោបាយ លែងមានសេចក្តីទុកចិត្តគ្នា ទៅវិញទៅមក។ ម្ខាង ចោទប្រកាន់ ដល់ម្ខាងទៀត ហើយទៅវិញទៅមក មិនចេះចប់សោះ។ ខ្មែរភាគច្រើន លែងមាន ការទុកចិត្ត លើកងទ័ព និង អ្នកនយោបាយ។ កូនទាហ៊ាន លែងទុកចិត្ត លើមេរបស់ខ្លួន, មេបញ្ជាការសឹកនៅលើសមរភូមិ លែងទុកចិត្ត លើអគ្គមេបញ្ជាការកងទ័ព, កងឯកភាពនិមួយៗ លែងទុកចិត្តគ្នានៅពេល ធ្វើប្រតិបត្តិការសឹករួម។ នៅទីបញ្ចប់ គឺកិត្យានុភាព របស់លោក លន់ នល់ ផ្ទាល់ ធ្លាក់ចុះដល់កំរិតទាបបំផុត ដែល នាំឲប៉ះពាល់ ដល់ តម្លៃ នៃរបបសាធារណរដ្ឋខ្មែរ តែម្តង។ ដូច្នេះ ដៃឆ្វេង និង ដៃស្តាំ វាមិនបានរួមគ្នា វៃខ្មាំងយួនកុម្មុយនិស្តនោះទេ ថែមទាំង វាវៃគ្នា ទៅវិញទៅមក ថែមទៀត៕